# អ្នកនាំសារ
# The Messenger

ឆ្នាំគ្រួសារ ២០១៧-២០២០

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមេសា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១១០



**សូមព្រះជាម្ចាស់ប្រទានព្រះពរឲ្យអស់បងប្អូន !**

"សូមឲ្យបងប្អូងបានពោរពេញសេចក្តីសុខសាន្តនឹងបានទទួល
ទឹកព្រះពរ ពីស្ថានលើដោយមានផ្កាម្លិះ និង
ផ្ការំដួលធ្លាក់ចុះមក ដើម្បីណែនាំឲ្យយើងទាំងអស់
ពោរពេញដោយអំណរ មេត្តាករុណា សម្រាប់ឆ្នាំថ្មីនេះ ។"

# សួស្តីឆ្នាំថ្មី

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខៈ ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ប្រមុខរាជរដ្ឋាភិបាលប្រកាសបន្ថែមការចូលរួមមូលនិធិគន្ធបុប្ផាកម្ពុជា




រូបភាពពីហ្វេសបុក សម្តេច ហ៊ុន សែន

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជានៅព្រឹកថ្ងៃទី១១ ខែមេសា បានប្រកាសពីការបរិច្ចាគប្រាក់ក្នុងមួយឆ្នាំ ៥ ម៉ឺនដុល្លារអាមេរិកក្នុងរយៈពេល៥ឆ្នាំ ទៅឲ្យមូលនិធិគន្ធបុប្ផាកម្ពុជា ខណៈដែលមូលនិធិនេះ តែងតែទទួលការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលស្រាប់ ដើម្បីបន្តបេសកម្មមនុស្សធម៌របស់មន្ទីរពេទ្យនេះ។

សម្តេចតេជោ នាយករដ្ឋមន្ត្រីបានប្រកាសបរិច្ចាគថវិកានេះ នៅក្នុងពិធីប្រកាសដាក់ឲ្យដំណើរការជាផ្លូវការនូវ "មូលនិធិគន្ធបុប្ផាកម្ពុជា" នាព្រឹកថ្ងៃទី១១ ខែ មេសា នៅវិមានសន្តិភាព។

សម្តេចតេជោហ៊ុន សែន បានមានប្រសាសន៍ថា "មូលនិធិគន្ធបុប្ផាកម្ពុជា " គឺជាថ្ងៃប្រវត្តិសាស្ត្រមួយដែលកុមារកម្ពុជានឹងបន្តទទួលបានការធានា នូវការគាំពារផ្នែកសុខភាពប្រកបដោយគុណភាព និងដោយមិនគិតថ្លៃ។

ក្នុងឱកាសនោះសម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានបង្ហាញការសោកស្តាយជាខ្លាំងដែរ ដោយលោកសាស្ត្រាចារ្យ ប៊ិត រិចឆន័រ ដែលជាវីរបុរស និងជាស្ថាបនិកនៃ "មូលនិធិគន្ធបុប្ផាប្រទេសស្វីស" មិនអាចមានវត្តមានក្នុងឱកាសជាប្រវត្តិសាស្ត្រនេះបាន ព្រោះឥឡូវនេះលោកបានសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យនៃប្រទេសស្វីស ប៉ុន្តែសម្តេច បានប្រកាសថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការលះបង់ និងការបរិច្ចាគពីចម្ងាយ ជូនលោក វេជ្ជ បណ្ឌិត ។

សម្តេចតេជោ ហ៊ុន សែន បានវាយតម្លៃយ៉ាងខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់របស់សាស្ត្រាចារ្យ ប៊ិត រិចឆន័រ ដែលបានលះបង់អស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធានហិរញ្ញវត្ថុ ដើម្បីកសាងនូវសមិទ្ធផលធំៗជាច្រើន ក្នុងរយៈពេល ២៥ឆ្នាំកន្លងមកនេះ សម្រាប់ជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជា និងដល់កុមារកម្ពុជា។

សម្តេចតេជោហ៊ុន សែន បានអះអាងជាថ្មីម្តងទៀតពីការគាំទ្ររបស់សម្តេច និងរាជរដ្ឋាភិបាលរបស់លោកយ៉ាងពេញទំហឹងចំពោះការបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជា។

សម្តេចតេជោ បានបញ្ជាក់ផងដែរថា មូលនិធិគន្ធបុប្ផាកម្ពុជាត្រូវបានបង្កើតឡើងមែន ប៉ុន្តែមូលនិធិនេះមិនជំនួសឲ្យ "មូលនិធិគន្ធបុប្ផាប្រទេសស្វីស" នោះទេ។ មូលនិធិពីប្រទេសស្វីសនៅតែមានសារៈសំខាន់សម្រាប់ដំណើរការមន្ទីរពេទ្យគន្ធបុប្ផា។ មូលនិធិទាំងពីរនឹងដំណើរការទន្ទឹមគ្នាហើយកិច្ចសហការជាមួយ "មូលនិធិគន្ធបុប្ផាប្រទេសស្វីស" នៅតែមានសារៈសំខាន់ចំពោះកិច្ចដំណើរការនៃមន្ទីរពេទ្យនេះទាំងមូល។

បើយោងតាមការពន្យល់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសប្បុរសជនដែលចូលវិភាគទាន៨០លានរៀល (២ម៉ឺនដុល្លារអាមេរិក) ឡើងទៅនឹងក្លាយជាសមាជិកស្ថាបនិក។ អ្នកចូលថវិកា៥ពាន់ដុល្លារឡើងទៅសមាជិកកិត្តិយស និងអ្នកចូលរួមថវិកា៥០០០រៀលក្នុងមួយខែ (៦ ម៉ឺនរៀលក្នុងមួយឆ្នាំ) ជាសមាជិកគាំទ្រ។ រាជរដ្ឋាភិបាលទុករយៈពេល ៣ខែ ដើម្បីឲ្យសប្បុរសជននានាចូលរួមជាសមាជិកនៃមូលនិធិនេះ។ សម្តេចតេជោនាយករដ្ឋមន្ត្រីសង្ឃឹមថា តាមរយៈសកម្មភាពនេះនឹងមាន ការចូលរួមពីសប្បុរសជនជាច្រើនបន្ថែមទៀតដើម្បីរួមចំណែកជួយដល់កុមារកម្ពុជារបស់យើងដែលកំពុងត្រូវការជួយសង្គ្រោះជារៀងរាល់ថ្ងៃ។

សូមបញ្ជាក់ថាក្នុងរយៈពេល ២៥ឆ្នាំ គិតចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០១៧ មន្ទីរពេទ្យគន្ធបុប្ផា បានចំណាយថវិកាអស់ជិត៦០០លានដុល្លារ ក្នុងបេសកកម្មសង្គ្រោះជីវិតកុមារក្រីក្ររបស់កម្ពុជា។ មន្ទីរពេទ្យគន្ធបុប្ផាបានចំណាយថវិកាប្រមាណ ៤២,៣ លានដុល្លារអាមេរិកក្នុង១ឆ្នាំ ដែលក្នុងនោះចំណាយទៅលើបន្ទុកបុគ្គលិកមានប្រមាណ ២២,៩លានដុល្លារ ចំណាយទិញឱសថ និងសម្ភារពេទ្យមានប្រមាណ ១៤,៤ លានដុល្លារ និងចំណាយប្រតិបត្តិការទូទៅមានប្រមាណ ២លានដុល្លារ ដោយថវិកាសម្រាប់ដំណើរការរបស់មន្ទីរពេទ្យនេះ គឺបានមកពីប្រភពរដ្ឋាភិបាលប្រទេសស្វីស រាជរដ្ឋាភិបាលកម្ពុជា និងសប្បុរសជនជាតិ និងអន្តរជាតិនានា។

ដោយអរិយបុត្រ

## សន្តសន្តី



សន្ត ឡូរង់

លោកឡូរង់ជាឧបដ្ឋាកដើមដំបូងនៅក្នុងចំណោមឧបដ្ឋាកទាំងប្រាំពីរនៃព្រះសហគមន៍ ទីក្រុងរ៉ូម។ គាត់មានតួនាទីជាជំនួយការរបស់សម្តេចប៉ាបជាពិសេសនៅពេលថ្វាយអភិបូជា និងផ្តល់ព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទ ដែលមានជំងឺមិនអាចទៅព្រះវិហារ។ ម៉្យាងទៀត គាត់ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ព្រះសហគមន៍ដោយចែកតង្វាយរបស់គ្រីស្តបរិស័ទដល់ជនក្រីក្រ។ នៅពេលដែលអាជ្ញាធរចាប់សម្តេចប៉ាបសីស្ត កាត់ទោសប្រហារជីវិត ឡូរង់សោកស្តាយថា ខ្លួនឯងមិនអាចបូជាជីវិតជាមួយព្រះអង្គដែរ តែសម្តេចប៉ាបលួងលោមគាត់ថា "កុំយំកូនអើយ! បីថ្ងៃទៀតកូននឹងដើរតាមខ្ញុំ"។ បី ថ្ងៃក្រោយមកអាជ្ញាធររ៉ូម៉ាំងចាប់ឡូរង់។ ពេលលោកទេសាភិបាលបញ្ជាគាត់ឲ្យប្រគល់ទ្រព្យសម្បត្តិព្រះសហគមន៍ ឡូរង់ប្រមូលអ្នកក្រីក្រ និងអ្នកជំងឺទាំងអស់ដើម្បីបង្ហាញ គេឲ្យលោកឃើញ ទាំងមានប្រសាសន៍ថា នេះហើយ គឺជាទ្រព្យសម្បត្តិរបស់ព្រះសហគមន៍។ យោងទៅតាមរឿងបុរាណដ៏ល្បីល្បាញនគរបាលដាក់លោកឡូរង់អាំងនៅលើភ្លើង។ មួយរយៈក្រោយមក គាត់និយាយថា អ្នកអាចប្រែខ្ញុំ ដើម្បីឲ្យខ្លួនខ្ញុំឆ្អិនទាំងអស់។ លោកឡូរង់ទទួលមរណភាពនៅឆ្នាំ២៥៨៕

# កម្ពុជាមានសហគមន៍ជនជាតិចិនសរុបប្រមាណជាជាង ១ លាននាក់

លោកឧកញ៉ា ពុង ឃាវសែ ប្រធានសមាគមសម្ព័ន្ធខ្មែរ-ចិន នៅព្រះរាជាណាចក្រកម្ពុជាបានឲ្យដឹងថា នៅទូទាំងប្រទេសកម្ពុជាមានសហគមន៍ជនជាតិចិនសរុបប្រមាណជាជាង ១លាននាក់។

លោកមានប្រសាសន៍ នៅក្នុងពិធីពិសាបាយសាមគ្គីរវាងសហគមន៍ចិន និងសម្តេចតេជោ ហ៊ុន សែន កាលពីល្ងាចថ្ងៃទី១០ ខែមេសាថា បច្ចុប្បន្នបងប្អូនខ្មែរចិន អាណិកជនចិននៅកម្ពុជាមានចំនួនប្រមាណ ១លាននាក់ ក្នុងនោះកូនចៅចិន ដែលមានកំណើតនៅប្រទេសខ្មែរប្រមាណ ៨សែននាក់ ហើយជនជាតិចិន ដែលមកពីចិន ហុងកុង ម៉ាកាវ និងតៃវ៉ាន់ មានចំនួនប្រមាណ២សែននាក់។

លោកបានបន្តទៀតថា បណ្តាសហគមន៍ជនជាតិចិនទាំងនោះ បានចងក្រងគ្នាជាសមាគមផ្សេងៗចំនួន១៤០ សមាគម រួមមានសមាគមនចិននិកាយទាំង៥ ដែលរួមមានដូចជា សមាគមចិនទៀជីវ សមាគមចិនកន្តាំង សមាគមចិនខិ សមាគមចិនហាយណាន សមាគមចិនហុកគៀន ដោយសមាគមត្រកូលទាំង ១៣សាខាសមាគមខ្មែរចិន នៅ២៥ខេត្តក្រុង និងសាលារៀនចិននៅទូទាំងប្រទេសកម្ពុជាចំនួន៥០គ្រឹស្ថាន ដែលកំពុងតែផ្តល់ការអប់រំដល់សិស្សានុសិស្សចំនួន៥ម៉ឺននាក់។

លោកបានបន្តទៀតថា បច្ចុប្បន្ននេះ នៅក្នុងទីក្រុងធំៗលើពិភពលោក នៅមានសមាគមខ្មែរចិនជាង១០សមាគមទៀត ដូចជា នៅទីក្រុមម៉ុងរ៉េអាល តូរ៉ុនតូ អូតាវ៉ា និងវ៉ានកូវើរ នៃប្រទេសកាណាដា ទីក្រុងឡូសអាន់ហ្សឺលេស ញ៉ូវយ៉ក, ប៊ុស្តុន, ស៊ីកាហ្គោ និងស៊ីអែថល នៃសហរដ្ឋអាមេរិក, ទីក្រុងប៉ារី ប្រទេសបារាំង, ទីក្រុងឡុងប្រទេសអង់គ្លេស, ទីក្រុងហ្វ្រែង្គហ្វដនៃប្រទេសអាល្លឺម៉ង់, ទីក្រុងមែលប៊ននិងស៊ីដនីនៃប្រទេសអូស្ត្រាលី, ទីក្រុងអូកឡែននៃប្រទេសណូវែលសេឡង់ ព្រមទាំងទីក្រុងហុងកុង។

លោកបានបន្តទៀតថា ការបង្កើតសមាគមសម្ព័ន្ធខ្មែរ ចិន នៅព្រះរាជាណាចក្រកម្ពុជា គឺមានបំណងផ្អែកលើកំលាំងរបស់បងប្អូនចិននៅកម្ពុជាដើម្បីជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ម៉្យាងសមាគមសម្ព័ន្ធខ្មែរចិនក៏បានធ្វើការផ្សព្វផ្សាយទាក់ទាញបងប្អូនខ្មែរចិន ដែលរស់នៅបរទេសឱ្យត្រលប់មកបណ្តាក់ទុននៅកម្ពុជា។

លោកឧកញ៉ា ពុង ឃាវសែ បានថ្លែងថា សមាគមនឹងអនុវត្តតាមគោលនយោបាយបើកទូលាយរបស់សម្តេចតេជោក្នុងការធ្វើជាស្ពានជំរុញសហប្រតិបត្តិការវិស័យវប្បធម៌ ហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ពន្ធ ឧស្សាហកម្ម កសិកម្ម និងទេសចរណ៍រវាងកម្ពុជា និងចិន។



រូបភាពពីហ្វេសបុក សម្តេច ហ៊ុន សែន

នាឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ដែលបានចូលរួមពិសារអាហារពេលល្ងាច បានថ្លែងថា នេះជាការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចំពោះសុខដុមនីយកម្មជនជាតិ និងសាសនានៅកម្ពុជា។

សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានថ្លែងក្នុងនាមរាជរដ្ឋាភិបាល បញ្ជាក់ឡើងវិញអំពីនយោបាយចិនតែមួយ ដែលនយោបាយការបរទេសរបស់កម្ពុជា ប្រកាន់យកតាំងពីដើមរហូតមកដល់បច្ចុប្បន្ន។

សម្តេចតេជោបានបន្តថា ការទទួលស្គាល់នយោបាយចិនតែមួយ គឺមានន័យស្មើ នឹងការគោរពអធិបតេយ្យភាពរបស់ប្រទេសចិន វាស្មើ នឹងការគោរពចំពោះអធិបតេយ្យភាពរបស់កម្ពុជាផងដែរ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើងនយោបាយទៅមុខទៀតរបស់កម្ពុជា គឺការទាក់ទាញ វិនិយោគ និងទេសចរណ៍ចិនមកកាន់កម្ពុជាឲ្យបានច្រើនថែមទៀត។

សម្តេចតេជោក៏បានអំពាវនាវឲ្យបងប្អូនជនជាតិចិននៅកម្ពុជាទាំងអស់ខិតខំជម្រុញឲ្យយុទ្ធសាស្ត្រ ដែលដាក់ចេញដោយប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរកម្ពុជាចិន បានដាក់ចេញនាពេលកន្លងមក។ នៅក្នុងឆ្នាំ២០១៧កន្លងទៅ ទំហំពាណិជ្ជកម្មកម្ពុជាចិនបានកើនឡើងដល់ ៥០០០ លានដុល្លារអាមេរិក និងទាក់ទាញទេសចរចិនឲ្យបានចំនួន ១,២ លាននាក់៕

ដោយ អរិយបុត្រ

# ការលេងល្បែងប្រជាប្រិយខ្មែរមានការធ្លាកចុះ

នៅក្នុងសង្គមខ្មែរ តាំងពីបុរាណកាលមកឲ្យតែដល់ពិធីចូលឆ្នាំខ្មែរម្តងៗ នៅតាមបណ្តាវត្តអារាម ភូមិស្រុកនានា និងតាមសាលារៀនតែងតែមានការប្រមូលផ្តុំជួបជុំគ្នា លេងល្បែងប្រជាប្រិយខ្មែរ ប៉ុន្តែចូលមកដល់សម័យបច្ចេកវិទ្យាទំនើបនេះ បែរជាល្បែងទាំងនេះមិនត្រូវបានយុវជន ឬក្មេងៗខ្មែរចាប់អារម្មណ៍ និងភាគច្រើនមិនចេះលេងល្បែងប្រជាប្រិយរបស់ខ្លួនឡើយ។

បើនិយាយពីល្បែងប្រជាប្រិយខ្មែរមានច្រើនទម្រង់ផ្សេងៗគ្នាដូចជា បោះអង្គុញ លាក់កន្សែង ស្តេចចង់ ទាញព្រ័ត្រ ក្រុងមេមាន់ វាយក្អម ឆ្មាចាប់កណ្តុរ ដណ្តើមស្លឹកឈើ ពង្រត់កូនក្រមុំ ចាប់កូនខ្លែងជាដើម។ តាមការអង្កេតរបស់មន្ត្រីផ្នែកវប្បធម៌បានបង្ហាញថា ក្នុងរយៈកាលចុងក្រោយនេះ ល្បែងប្រជាប្រិយខ្មែរហាក់មានការធ្លាក់ចុះជាខ្លាំង ស្ទើរតែជនជាតិខ្មែរខ្លួនឯងមិនស្គាល់ថា អ្វីជាល្បែងប្រជាប្រិយខ្មែរ ហើយក៏មិនដឹងពីរបៀបលេងល្បែងប្រជាប្រិយ ដែលជាវប្បធម៌របស់ខ្លួនឡើយ។

យុវជន សុខហួរ អាយុ២៧ឆ្នាំ បាននិយាយថា គាត់មិនចូលចិត្តលេងល្បែងប្រជាប្រិយរបស់ខ្មែរទេ ហើយគាត់ក៏មិនចេះពីរបៀបលេងដែរ។ សុខហួរថា "និយាយឲ្យត្រង់ចុះ ខ្ញុំមិនចូលចិត្តទាល់តែសោះ។ ការលេង និងចំណង់ចំណូលចិត្ត គឺអាស្រ័យលើមនុស្សម្នាក់ៗ អ្នកខ្លះគេចូលចិត្ត អ្នកខ្លះមិនចូលចិត្ត ដូចខ្ញុំជាដើម មិនដែលលេង ហើយក៏គ្មានចំណូលចិត្តលើល្បែងប្រជាប្រិយដែលជាកេរ្តិ៍តំណែលវប្បធម៌របស់ខ្លួនដែរ"។ សុខហួរបន្តថា កុំថាឡើយមិនចេះលេង មិនចូលចិត្តតែថែមទាំងស្អប់ទៀតផង។ ដោយសារមើលទៅជាល្បែងមួយដែលគួរឲ្យធុញទ្រាន់ មិនមានចំណុចណាមួយ ដែលលេងហើយធ្វើឲ្យសប្បាយឡើយ។

សុខហួរបន្ថែមថា ជាធម្មតានៅរដូវចូលឆ្នាំខ្មែរ លោកតែងតែធ្វើការងារដូចជាថ្ងៃធម្មតាដែរ គឺលោកភ្ញាក់ពីគេងលឿន លំហែអារម្មណ៍ដោយការមើលភាពយន្តបរទេសតាមដានព័ត៌មានតាមរយៈបណ្តាញសង្គម ប៉ុន្តែអ្វីដែលប្លែកជាងសព្វមួយដងគឺ "ជួយលក់ដូរអីវ៉ាន់របស់ម្តាយរបស់ខ្ញុំ ដែលបើកហាងលក់គ្រឿងទេសនៅផ្ទះ"។

សុខហួរបញ្ជាក់ថា "ល្បែងប្រជាប្រិយ គេច្រើនតែលេងនៅតាមផ្ទះអ្នកស្រុក ឬវត្តអារាម ប៉ុន្តែសម្រាប់ខ្ញុំបើខ្ញុំចេញក្រៅជាមួយមិត្តភក្តិ គឺសុំជៀសវាងទៅក្នុងវត្តហើយ ដោយសារខ្ញុំមិនចង់ឃើញគេលេងល្បែងទាំងនោះទេ មើលទៅគួរឲ្យធុញ"។ សុខហួរបញ្ជាក់ថា ទោះបីជាខ្ញុំមិនចូលចិត្ត តែគ្មានបំណងចង់ឲ្យមនុស្សរាល់គ្នា ឬរដ្ឋាភិបាលលុបល្បែងប្រជាប្រិយខ្មែរ ចេញពីបញ្ជីរបស់វប្បធម៌ខ្លួនឡើយ។

ក្រុមជំនាញថែរក្សាវប្បធម៌ ប្រពៃណីជាតិបានលើកឡើងនូវមូលហេតុចម្បងៗមួយចំនួននៃការប្រឈមនូវការបាត់បង់ល្បែងប្រជាប្រិយខ្មែរ ដោយពួកគេបានបង្ហាញនូវកត្តាមួយចំនួនដូចជា កត្តាខ្វះគំនិតមោទនវប្បធម៌ជាតិនិយម ឥទ្ធិពលវប្បធម៌អឺរ៉ុប ចូលខ្លាំងមែនទែននៅក្នុងសង្គមខ្មែរ។ កត្តានយោបាយ ការបែងចែកព័ណ៌សម្បុរនយោបាយ នេះក៏ជាទិដ្ឋភាពចម្បងនៃការធ្វើឲ្យបាត់បង់ល្បែងប្រជាប្រិយមរតកអរូបិយខ្មែរផងដែរ។ កត្តាសីលធម៌សង្គម ដោយចម្លងបាននូវវប្បធម៌កេងបន្លំ កេងចំណេញ និងឆ្មក់ឱកាស យុវជនមួយចំនួនបានឆ្លៀតឱកាសក្នុងពិធីលេងល្បែងប្រជាប្រិយ តែងឆ្លៀតឱកាសធ្វើអំពើអសីលធម៌ដូចជា លូកលាន់លើរាង្គកាយនារីភេទ បេះបោចសម្ភារ មានគ្រឿងអលង្ការជាដើម...។ល។

កត្តាសហគមន៍ កន្លែងអាណាធិបតេយ្យ គ្មានការគ្រប់គ្រងត្រឹមត្រូវ ម៉ត់ចត់ សម្បូរល្បែងស៊ីសង ស្រីស្រា គ្រប់ប្រភេទ។ ទោះបីជាមានកត្តារាំងយ៉ាងណាក៏ដោយ ការថែរក្សា ការអភិរក្សមកលើវប្បធម៌ខ្មែរ ល្បែងប្រជាប្រិយខ្មែរ គឺមិនត្រូវជាន់ពន្លិច ឬបំភ្លេចចោលនោះឡើយ។ ត្រូវចងចាំថា "វប្បធម៌រលត់ ជាតិរលាយ"។



# អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ផ្លាស្ទិកមាន តែការប្រែប្រួលដូចជាមិនមានធំដុំ

ប្រជាពលរដ្ឋកម្ពុជាបានទទួលស្គាល់ថា ផ្លាស្ទិកគឺពិតជាមានផលប៉ះពាល់ចំពោះបរិស្ថាន សោភ័ណភាព និងអេកូឡូស៊ីផ្សេងៗ នៅក្នុងប្រព័ន្ធធម្មជាតិ ប៉ុន្តែពួកគេនៅតែមានការលំបាកនៅក្នុងការបោះបង់វា។

លោកស្រី ទិត្យ សុកញ្ញា ជាស្ត្រីមេផ្ទះមួយរូប បានអះអាងថា តាមការអាន ការស្តាប់ ការផ្សព្វផ្សាយ គឺនរណាក៏ដឹង នរណាក៏យល់អំពីផលប៉ះពាល់របស់សំរាម ជាពិសេសគឺផ្លាស្ទិកនេះដែរ ប៉ុន្តែវាលំបាកនៅក្នុងការបំភ្លេចវាចេញពីជីវភាពរបស់លោកស្រីនិង ក្រុមគ្រួសារលោកស្រី។

លោកស្រីបានកញ្ញាបានបញ្ជាក់ថា "ខ្ញុំធ្លាប់គិតថា បោះបង់វាចោលដែរ ប៉ុន្តែវាធ្វើមិនបាន។ បើងាកទៅណាក៏ជួបផ្លាស្ទិកដែរតាំងពីនៅផ្ទះ ផ្សារ កន្លែងដើរលេង នៅកន្លែងធ្វើការ គឺស្ទើក៏ត្រូវការផ្លាស្ទិក"។ លោកស្រីបានបន្តទៀតថា ឥឡូវនេះលោកស្រីកំពុងតែព្យាយាមកាត់បន្ថយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដូចជា មិនជោគជ័យខ្លួនឯង ដោយសារតែវាចេះតែត្រូវការ។

លោក ជា ចេងសីហា ជាប្រជាពលរដ្ឋមួយរូបបានអះអាងថា ឥឡូវនេះលោកអាចចូលរួមត្រឹមការកាត់បន្ថយ ពីព្រោះថាបើលុបបំបាត់ផ្លាស្ទិកតែម្តង គឺមិនអាចទេ ប៉ុន្តែលោកក៏បានទទួលស្គាល់អំពីការលំបាកនៅក្នុងការកាត់បន្ថយនេះផងដែរ។

លោកបានបញ្ជាក់ថា "បើដូចកាលពីទសវត្សរ៍នៃឆ្នាំ១៩៨០ មកមានអី! កាលពេលនោះ យើងមានថង់ផ្លាស្ទិកមួយៗ មានតែស្លឹកចេក និងស្លឹកឈូក វេចខ្ចប់ ទាំងខ្ញុំទាំងគេមិនប្រើតែសម័យនេះ វាទម្លាប់ប្រើថង់ផ្លាស្ទិកហើយ បានស្លឹកចេក និងស្លឹកឈូក ពីណាមកទៀត"។

លោកបានបញ្ជាក់ទៀតថា "មនុស្សកាលណាទម្លាប់ប្រើអារបស់ស្រួល វាចេះតែចង់ស្រួល ហើយគ្មាននរណាចង់វេចស្លឹកចេក ស្លឹកឈូក ប៉េកប៉ាក នោះទេ។ ជាពិសេសអ្នកលក់"។

លោកស្រី ចេង សុភ័ក្រ អ្នកលក់បាយព្រឹកមួយរូប បានឲ្យដឹងថា សម័យនេះហើយទៅរកស្លឹកឈូក និងស្លឹកចេកពីណាមកខ្ចប់បាយ។ លោកស្រីបានបន្តទៀតថា លោកស្រីក៏ចង់ចូលរួមកាត់បន្ថយថង់ផ្លាស្ទិក និងប្រអប់បាយស្នោដែរ ប៉ុន្តែវាអត់មានជម្រើស។

លោកស្រីបានបញ្ជាក់ថា "ស្មានតែ ខ្ញុំចង់ប្រើផ្លាស្ទិក និងប្រអប់ស្នោណាស់ទៅ តែវាអត់មានជម្រើស បើអ្នកខ្លះគាត់យល់ដឹង គាត់មកអង្គុយញ៉ាំនៅកន្លែងមានអី ហើយអ្នកខ្លះគាត់ខ្ចប់ដែរ តែមាន ប្រអប់ដាក់ គឺខ្ញុំអរ"។

លោកស្រីបានបន្តថា សព្វថ្ងៃនេះមានអ្នកដែលយល់ដឹងខ្លះគាត់មិនយកប្រអប់ស្នោ ឬថង់ផ្លាស្ទិក សម្រាប់ដាក់ទឹកស៊ុបទេ តែគាត់មានប្រអប់របស់គាត់ ផ្ទាល់ខ្លួន ដោយអ្នកខ្លះមានរបស់គាត់ផង របស់គ្រួសារគាត់ផង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយអ្នកដែលមានប្រអប់ផ្ទាល់ខ្លួនបែបនេះមិនសូវមានទេ ដោយសារប្រហែលពួកគេខ្ជិលលាង អាងតែបរិភោគហើយបោះចោ។

លោកស្រីបានបន្តទៀតថា មានការផ្សព្វផ្សាយអំពីការហាមឃាត់ និងការអប់រំរឿងបរិស្ថាន និងរឿងសំរាមនេះដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាគឺពិបាកអនុវត្តណាស់ ហើយមកដល់ពេលនេះ លោកស្រីអះអាងថា ជាទូទៅបរិមាណនៃថង់ផ្លាស្ទិក និងប្រអប់ស្នោ បំពង់បឺ គឺនៅតែដដែល គឺ មួយថ្ងៃលោកស្រីអាចប្រើថង់ផ្លាស្ទិក ពី ២ទៅ៣ខាំ ប្រអប់ស្នោ ១០០ ទៅ ១៥០ប្រអប់។

លោក សេក សុបិន្ត ជាមន្ត្រីសង្គមស៊ីវិលមួយរូប បានឲ្យដឹងថា មានអនុក្រឹត្យស្តីរឿងសំរាមផ្លាស្ទិកនេះ ប៉ុន្តែដូចជាមិនមានការថយចុះសោះ។ លោកបានបន្តទៀតថា តាមផ្សារ ពិសេសផ្សារទំនើប គឺនៅតែប្រើថង់ប្លាស្ទិក ឯគោលគំនិតឲ្យផលិតជាថង់ក្រដាសវេចខ្ចប់ ដូចជាមិនបានឃើញ។

លោកបានបញ្ជាក់ថា "តាំងពីមានអនុក្រឹត្យនេះ និងមិនទាន់មាន គឺដូចជាដដែល អ្នកប្រើនៅតែប្រើ។

រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងបរិស្ថានជាក្រសួងជំនាញកាលពី ខែតុលា ឆ្នាំទៅ បានចេញអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ផ្លាស្ទិកក្នុងគោលបំណងបង្កើនប្រសិទ្ធភាពលើការកាត់បន្ថយ ការនាំចូល ការផលិត និងការប្រើប្រាស់ថង់ផ្លាស្ទិក សំដៅកាត់បន្ថយផលប៉ះពាល់សុខភាព និងបរិស្ថាន។

អនុក្រឹត្យដែលចេញដោយក្រសួងបរិស្ថាននេះមានគោលដៅសំខាន់ៗដូចជា កំណត់តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នជំនាញ លើការនាំចូល ការផលិត ការចែកចាយ ការប្រើប្រាស់ និងការកែច្នៃសំណល់ថងផ្លាស្ទិក។ ជាមួយគ្នានោះ អនុក្រឹត្យដដែលក៏កំណត់ពីការគិតកម្រៃបន្ថែមលើការប្រើប្រាស់ថង់ផ្លាស្ទិករបស់អតិថិជន និងអប់រំឲ្យប្រជាពលរដ្ឋកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិក ព្រមទាំងលើកទឹកចិត្តដល់វិស័យឯកជនឲ្យកែច្នៃសំណល់ថង់ផ្លាស្ទិកនៅក្នុងស្រុក និងការផលិតសម្ភារផ្លាស្ទិកដែលងាយពុកផុយ។ អនុក្រឹត្យនេះគឺមានបំណងលើកទឹកចិត្តឲ្យប្រជាជនប្រើប្រាស់ស្លឹករុក្ខជាតិដូចជាស្លឹកឈូក និងស្លឹកចេក មកវេចខ្ចប់ចំណីអាហារ ឬទំនិញជំនួសឲ្យការប្រើប្រាស់ថង់ផ្លាស្ទិក។

តាមការសិក្សារបស់អង្គការមូលនិធិ-អាក្រានៅឆ្នាំ២០១៦ ដែលបានដកស្រង់ដោយសារព័ត៌មាន បានឲ្យដឹងថា កម្ពុជាត្រូវចំណាយលុយប្រចាំឆ្នាំជាង៥ម៉ឺនដុល្លារលើសម្ភារសម្អាតថង់ផ្លាស្ទិក ក្នុងនោះ ៤.៥០០ដុល្លារ ក្នុងខេត្តព្រះសីហនុ ១៥.០០០ដុល្លារ នៅខេត្តសៀមរាប និង ៣១.០០០ដុល្លារនៅភ្នំពេញ។ ការសិក្សាលើប្រជាពលរដ្ឋជាង ២០០នាក់ បញ្ជាក់ថា ពួកគេត្រូវបាត់បង់ចំណូលជាមធ្យម ១០៣ដុល្លារ ក្នុងមួយខែដោយសារស្ទះលូ ដែលជាមូលហេតុពីថង់ផ្លាស្ទិក។

តាមរបាយការណ៍មួយ ដែលប្រកាសដោយក្រសួងបរិស្ថានបានឲ្យដឹងថា ជាទូទៅប្រជាពលរដ្ឋកម្ពុជា អាចប្រើប្រាស់ថង់ផ្លាស្ទិក ប្រហែលជា១០លានថង់នៅក្នុងមួយឆ្នាំ ដោយពលរដ្ឋម្នាក់ៗ ជាពិសេសអ្នក ដែលរស់នៅតំបន់ទីក្រុងនិងទីប្រជុំជន គឺអាចប្រើជាមធ្យមនៅក្នុងមួយថ្ងៃ៥ ថង់។

នេះគឺជាតួលេខនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបើនៅសាកលវិញ គេបានបានប្រមាណថា មកដល់ពេលនេះ ថង់ផ្លាស្ទិកប្រមាណជា ៣ ពាន់លានថង់ត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋ ទាំងអស់នៅលើពិភពលោក៕ *ដោយ អរិយបុត្រ*



*រូបភាពឯកសារ ថតដោយៈ អរិយបុត្រ*

# យុវជនមួយក្រុមបានរួមគ្នាផលិតផ្សិតដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក



ថតដោយៈ កញ្ញា

ក្នុងដីឡូមួយកន្លែងដែលមានប្រមាណជាកន្លះហិកតា នៅតំបន់ចំការដូងក្នុងរាជធានីភ្នំពេញ មានល្បាយអាចម៍រណាជាច្រើនដែលបានលាយ និងច្រកជាកញ្ចប់តូចៗត្រូវបានដាក់គរលើគ្នា ហើយខ្លះត្រូវបានទុកចោលមួយអន្លើ។ នៅលើធ្នើធ្វើអំពីដែក មានល្បាយខ្លះត្រូវបានរៀបជាន់លើគ្នាជាបីថ្នាក់ ដែលក្នុងមួយធ្នើអាចដាក់ល្បាយនេះបានប្រមាណ៧៥០ដុំ។ កំពុងអង្គុយដាក់សំលីចូលក្នុងគម្របសម្រាប់បិទមាត់ល្បាយទាំងនោះ យុវជនវ័យ២៣ឆ្នាំ ធួក តេកលាង បានឲ្យដឹងថា ទីនេះគឺជាដីឡូដែលក្រុមនិស្សិតបានចូលហ៊ុនគ្នាដើម្បីបង្កើតអាជីវកម្មមួយស្រាវជ្រាវ ផលិត និងចែកចាយផ្សិត។

តេកលាងបានប្រាប់ទៀតថា ពួកគាត់មានបទពិសោធន៍អំពីការផលិតផ្សិតអំបោះ ឬផ្សិតស អ្នកខ្លះជាងមួយឆ្នាំ អ្នកខ្លះទៀតក៏ច្រើនជាងនេះ។ តេកលាងបញ្ជាក់ថា "កាលពីមុនពួកខ្ញុំធ្វើនៅក្នុងសាលា ដោយសារគ្រូចង់ឲ្យពួកខ្ញុំ Share (ចែករំលែក) ចំណេះដឹងដល់សិស្សប្អូនផ្សេងៗទៀត។ អីចឹងពួកខ្ញុំក៏ធ្វើនៅក្នុងសាលា។ ហើយពួកខ្ញុំគិតថា នៅក្នុងសាលាវាកន្លែងតូចពេក ពួកខ្ញុំពិបាកពង្រីកកន្លែង អីចឹងពួកខ្ញុំក៏ចាប់ផ្តើមមកជួលកន្លែងក្រៅ ធ្វើអាជីវកម្មកន្លែងថ្មីហ្នឹង។ អីចឹងវាទើបតែដំណើរការបានប៉ុន្មានខែហ្នឹងទេ"។

តាមការឲ្យដឹងរបស់លោកតេកលាង ក្រុមនិស្សិតមានចំនួន៥នាក់ ពួកគេភាគច្រើនជានិស្សិតដែលទើបបញ្ចប់ការសិក្សានៅសាលាកសិកម្មចំការដូង។ និយាយបណ្តើរធ្វើការងារបណ្តើរតេកលាងបានប្រាប់ថា អតិថិជនរបស់គាត់មួយចំនួនគឺជាកសិករដែលធ្លាប់បានធ្វើដំណាំផ្សិតនេះ ជាច្រើនលើកមកហើយដែរ ហើយខ្លះទៀតជានិស្សិតដែលចង់សាកល្បងបណ្តុះផ្សិត។

លោកធួក តេកលាង បានបន្ថែមទៀតថា "សម្រាប់អតិថិជន ពេលយកល្បាយយើងហើយ បើគាត់មានបញ្ហា គាត់អាចសួរយើងប្រឹក្សាជាមួយយើង។ ហើយជួនកាលល្បាយដែលយកទៅមានបញ្ហាតិចតួចអី គឺយើងសងគាត់វិញ គ្រាន់តែគាត់ប្រាប់ទិន្នន័យច្បាស់លាស់"។

លោកស៊ូណាន់ ចាន់ណារ៉ុង ជាមេក្រុមបានប្រាប់ថា កត្តាសំខាន់ដែលក្រុមនិស្សិតបានចាប់ផ្តើមកម្មវិធីនៅតំបន់នោះ គឺដើម្បីផ្គត់ផ្គង់នូវទីផ្សារក្នុងស្រុក ព្រោះកសិករកម្ពុជាមិនទាន់មានលទ្ធភាពផលិតផ្សិតដើម្បីផ្គត់ផ្គង់ទីផ្សារបានគ្រប់គ្រាន់នៅឡើយ ហើយគុណភាពនៃផ្សិតនៅមានកម្រិត។ លោកណារ៉ុង "ទីមួយទីផ្សារ ទី២ការផ្គត់ផ្គង់ អត់ទាន់តម្រូវការគ្រប់ទីផ្សារ ហើយណាមួយទៀតនៅយើងខ្វះបច្ចេកទេសច្រើន ហើយម្យ៉ាងទៀតផ្សិតយើងយកមកភាគច្រើនអត់មានគុណភាព មានន័យថា ផ្សិតដែលយកមកពីទីឆ្ងាយកសិករអត់ចេះរក្សាគុណភាព គេមើលទៅគេទំលាក់តម្លៃ តែប្រសិនបើយើងបណ្តុះនៅក្បែរក្រុង ការដឹកជញ្ជូនជិតយើងអាចរក្សាគុណភាពបានល្អតម្លៃវាថ្លៃជាង"។

លោកណារ៉ុង បញ្ជាក់ថា ទិសដៅសំខាន់របស់ក្រុមនេះ គឺចង់បង្កើតនូវសមាគមអ្នកដាំផ្សិតដើម្បីគ្រប់គ្រង់តម្លៃទីផ្សារ និងការផលិតឲ្យបានត្រឹមត្រូវ។ យុវជនដដែលនេះប្រាប់ថា "សម្រាប់ខ្ញុំ ខ្ញុំចង់បង្កើតជាសមាគមផ្សិត មូលហេតុអី គឺពាក់ព័ន្ធនឹងការចែករំលែកបច្ចេកទេសគ្នា ដូចនៅខាងវៀតណាម មួយឆ្នាំគេបើកសិក្ខាសាលាផ្លាស់ប្តូរបច្ចេកទេសគ្នា។ អីចឹងនៅខ្មែរយើងអត់ទាន់មាន។ អីចឹងបើចង(សមាគម)បានរឹតតែច្រើន យើងអាចបើកសិក្ខាសាលាបាន ទាក់ទងនឹងដោះដូរបច្ចេកទេសគ្នា ការបណ្តុះ ការថែទាំទីផ្សារ ការគ្រប់គ្រងតម្លៃទីផ្សារ"។

លោកណារ៉ុងបានរៀបរាប់ថា កន្លងមកកសិករដែលរកចំណូលក្នុងផ្នែកនេះ មានបញ្ហាប្រឈមជាច្រើន ពាក់ព័ន្ធនឹងការផ្គត់ផ្គង់ និងតម្លៃទីផ្សារតែម្តង។ លោកណារ៉ុង "បញ្ហាប្រឈមត្រង់ថា កសិករ ក ហ្នឹង គាត់ផលិតបានចំនួន៥០០គីឡូ ហើយ ខ គាត់ផលិតបាន៣០០គីឡូ។ ហើយពួកគាត់២នាក់ហ្នឹង អត់អាចផលិតបានរាល់ថ្ងៃទេ។ អីចឹង(ទិន្នផល)ឡើងចុះៗ ជួនកាលអត់មានផង។ អីចឹងធ្វើឲ្យឈ្មួញគាត់ពិបាក គាត់ត្រូវនាំផ្សិតពីក្រៅមក។ យើងមិនប្រាកដថាអាចឲ្យគាត់បាន១០០% ទេ ហើយគាត់ក៏មិនថាយកពីយើង១០០% ដែរ។ គាត់ត្រូវការមួយគឺ ធ្វើម៉េចគឺមានទៀងទាត់ឲ្យគាត់ ព្រោះគាត់ត្រូវការឲ្យម៉ូយគាត់ដែរ។ អីចឹងតម្លៃ ជួនកាលបុកមក បីបួនម៉ូយអីចឹងក៏មានដែរ។ ក្នុងមួយថ្ងៃគាត់អាចយកត្រឹមមួយតោនទេ សុខៗបានដល់១,៥ ឬ២តោន ដូច្នេះ គាត់ត្រូវទំលាក់តម្លៃ"។

បច្ចុប្បន្នអាជីវកម្មរបស់ក្រុមនិស្សិតនេះគឺផលិតល្បាយ និងមេផ្សិតដើម្បីលក់ជូនប្រជាកសិករ និងនិស្សិតដូចគ្នាប៉ុណ្ណោះ។ ប៉ុន្តែរយៈកាលប៉ុន្មានឆ្នាំនេះ ផ្សិតហាក់ដូចជាមានការថយចុះនៅលើទីផ្សារ ជាពិសេសគឺផ្សិតចំបើង ដូច្នេះក្រុមរបស់គាត់គឺចង់ចាប់ផ្តើមគម្រោងនេះបន្ថែមទៀត។

មេក្រុមរូបនេះបានឲ្យដឹងយ៉ាងដូច្នេះថា "ក្នុងរយៈពេលបីបួនឆ្នាំមុនហ្នឹង ផ្សិតចំបើងមានការថយចុះក្នុងរដូវកាលបណ្តុះផ្សិតចំបើង ពីមុនសម្បូរបែប ជាពិសេសខាងបាទី តែឥឡូវបែជាស្ងាត់ឈឹងវិញ។ ដោយសារពាក់ព័ន្ធនឹងបច្ចេកទេស ពូជ អាកាសធាតុ គាត់អត់អាចគ្រប់គ្រងបានទាំងអស់។ អីចឹងគាត់ សុខចិត្តសម្រាក។ អីចឹងមានបញ្ហាមួយផ្សិតត្រូវការនាំចូល។ តាមបទពិសោធរបស់ខ្ញុំ ខ្ញុំស្គាល់ខាងវៀត-ណាមច្រើនគឺគេនិយាយថាគេប្រមូលផ្សិតដឹកមកខ្មែរច្រើន ដោយសារអីយើងអត់មានផ្សិតឲ្យគេសោះ"។

លោកស៊ូណាន់ ចាន់ណារ៉ុង ដែលបានធ្លាប់សិក្សាស្រាវជ្រាវអំពីពពួកផ្សិតបានឲ្យដឹងទៀតថា ជំហានបន្តទៅទៀតក្រុមពួកគាត់ចង់បង្កើតនូវផ្សិតច្រើនប្រភេទទៀតដូចជាផ្សិតថ្នាំ ផ្សិតចំបើង និងផ្សិតជង្គង់។ ហើយនៅក្នុងប៉ុន្មានខែបន្ទាប់នេះ នឹងមានរៀបចំការបណ្តុះផ្សិតស និងផ្សិតចំបើងដើម្បីយកផលលក់នៅលើទីផ្សារវិញម្តង។ ក្នុងការផលិតផ្សិត ក្រុមយុវជនទាំងនេះក៏បើកឱកាសដើម្បីឲ្យនិស្សិតដែលមានបំណងចង់ឈ្វេងយល់បន្ថែមលើការបណ្តុះផ្សិតមករៀនសាកល្បងជាមួយក្រុមពួកគាត់ផងដែរ៕

*ដោយកែវ កញ្ញា*

# កម្មករ និងកម្មការិនីសម្តែងការកក់ក្តៅនឹងការយកចិត្តទុកដាក់របស់អាជ្ញាធរ

ក្រុមកម្មករ និងកម្មការិនីរោងចក្រកាត់ដេរ ដែលបានទទួលការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា បានសំដែងការពេញចិត្តពេញថ្លើមនឹងការគាំពារក៏ដូចជាការផ្តល់នូវសេវាកម្មផ្សេងៗដល់ពួកគេ ខណៈដែលអ្នកខ្លះព្រួយបារម្ភថា អ្វីៗដែលពួកគេទទួលបាន ខ្លាចតែពួកគេទទួលត្រឹមឆ្នាំបោះឆ្នោត។

លោកស្រី ញឹម ស្រីចាន់ថា ជាកម្មការិនីមួយរូប នៅតំបន់ព្រៃទា បានថ្លែងថា តាំងពីលោកស្រីបានធ្វើជាកម្មការិនីមក កម្រមានអាជ្ញាធរណាយកចិត្តទុកដាក់ដល់កម្មករដូចជាពេលនេះណាស់។

លោកស្រីបានបញ្ជាក់ថា "យើងកក់ក្តៅនឹងការប្រកាសផ្តល់ឲ្យ និងបានឲ្យមកពួកយើង ដូចជារឿងសម្រាលកូនបានលុយ អត់អស់ថ្លៃពេទ្យ ..."។

ស្ត្រីកម្មការិនី ដែលជាម្តាយរបស់កុមារពីររូបរូបនេះបានថ្លែងថា ទោះបីជាលោកស្រីគ្មានគម្រោងនឹងយកកូននឹងគេតទៅទៀតក៏ដោយ ប៉ុន្តែលោកស្រីសប្បាយចិត្តនឹងឃើញការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ជាពិសេសគឺសម្តេចតេជោ ដែលប្រកាសរឿងឲ្យលុយស្ត្រីកម្មការិនីឆ្លងទន្លេសម្រាលកូនមិនយកប្រាក់ ហើយឈប់មានប្រាក់ខែលើសទៀត។

កញ្ញា សឿ ស្រីម៉ៅ ជាកម្មការិនីមួយរូប នៅរោងចក្រស្បែកជើង ម៉ុទួលសង្កែបានឲ្យដឹងថា កញ្ញាមិនទាន់បានទទួលសេវាកម្មរឿងមាតុភាពទេ ប៉ុន្តែកញ្ញាបានសាកល្បងទៅពេទ្យឃើញថា ពេលពិនិត្យគេអត់យកលុយទេ ហើយជិះឡានក្រុង ក៏គេមិនគិតប្រាក់ដែរ គ្រាន់តែបង្ហាញកាត់កម្មករទៅគេទៅ។

កញ្ញា បានបញ្ជាក់ថា កាលពីពេលថ្មីៗកន្លងទៅនេះ កញ្ញា ក៏មានឱកាសបានជួបសម្តេចតេជោ ហ៊ុន សែន នឹងគេដែរ ហើយអះអាងថា សម្តេចគាត់សាមញ្ញណាស់។

កញ្ញា បានបញ្ជាក់ថា "ខ្ញុំអត់បានថតសែលហ្វីជាមួយនឹងសម្តេច ហ៊ុន សែន នឹងគេផង ប៉ុន្តែបានចាប់ដៃពេលគាត់ដើរចូលកន្លែងជួបជុំ។

លោក ព្រាប សំរិទ្ធិសម្បត្តិ ជាអ្នកបើករថយន្តមួយរូបបានឲ្យដឹងថា វាពិតជាត្រេកអរមែនទែន។ ការផ្តល់ជូនរដ្ឋាភិបាលនេះ គឺពិតជាសមរម្យណាស់។ តាមការរៀបរាប់របស់ សម្បត្តិ ភរិយារបស់គាត់ដែលជាកម្មការិនីរោងចក្រមួយរូបថ្មីៗនេះបានឆ្លងទន្លេ ហើយពិតជាទទួលបានអ្វីៗតាមការសន្យានោះមែន។

សម្បត្តិបានបញ្ជាក់ថា "និយាយមិនអរ មិនសប្បាយម៉េចបង កាលកូនទីមួយខ្ញុំអស់លុយឡើង ៣០០ទៅ ៤០០ ដុល្លារ ពេលប្រពន្ធកើតកូន តែដល់កូនទីពីរ ធូមែនទែន បានកើតអត់អស់លុយ ហើយបានលុយ ៤០ម៉ឺនរៀលទៀត តែឮគឺថាគាត់(ភរិយារបស់សម្បត្តិ) មានប្រាក់ខែ ១២០ភាគរយទៀត ប៉ុន្តែមិនទាន់ដល់ពេលទៅបើក"។

សម្បត្តិបានបន្តទៀតថា សេវាកម្មដែលផ្តល់ឲ្យនេះ គឺវាកក់ក្តៅណាស់សម្រាប់កម្មករ និងកម្មការិនី ដែលមានប្រាក់ខែតិចហើយការងារហត់នឿយ។

ទន្ទឹមនឹងការសម្តែងការពេញចិត្តពេញថ្លើម នឹងសេវាកម្មផ្សេងៗ ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសផ្តល់ជូននោះ បណ្តាកម្មករទាំងនេះ មួយចំនួនក៏សម្តែងការព្រួយបារម្ភថា រាល់ការផ្តល់ជូនទាំងនេះ អាចមានតែនៅក្នុងពេលបោះឆ្នោត ដោយសារតែឆ្នាំនេះ គឺជាឆ្នាំបោះឆ្នោត។

លោក សម្បត្តិ បានអះអាងថា បើបានសេវាកម្មទាំងនេះ ផ្តល់ជូនប្រពន្ធ (កម្មករកាត់ដេរ) រហូតប្រសើរហើយ តែលោកខ្លាចបានតែឆ្នាំនេះ ដោយសារតែឆ្នាំនេះមានការបោះឆ្នោត។

សម្បត្តិបានបញ្ជាក់ថា "ខ្ញុំសង្ឃឹមថា រដ្ឋនឹងបន្តសេវាកម្ម និងការយកចិត្តទុកដាក់កម្មករបន្តទៀត ទោះបីជាបោះឆ្នោតហើយក៏ដោយ"។

កញ្ញាស្រីម៉ៅ បានឲ្យដឹងថា វាមិនច្បាស់ដែរហ្នឹង ពីព្រោះឆ្នាំនេះ ជាឆ្នាំបោះឆ្នោត ប៉ុន្តែបើតាមសម្តេចគាត់មានប្រសាសន៍កាលពេលបានជួប គឺថាសម្តេចបានសន្យាច្បាស់ណាស់ថា នឹងបន្តរហូត។

កញ្ញាបានបញ្ជាក់ដោយសើចផងអីផងថា "តិចដល់ខ្ញុំមានប្តីមានកូន លែងបាន ៤០ម៉ឺននឹងគេ ហើយកើតកូនពេទ្យទាលុយទៅ។ ខ្ញុំគិតយកប្តី យកកូននឹងគេហើយឆ្នាំនេះ"។

លោកស្រី ស្រីចាន់ថា ក៏បានបង្ហាញនូវក្តីសង្ឃឹមថា រាជរដ្ឋាភិបាលនឹងបន្តនយោបាយ និងសេវាកម្មទាំងអស់ ដូចដែលបានប្រកាសផ្តល់ជូនដល់កម្មករ ដោយសារអ្វីៗដែលរដ្ឋបានផ្តល់ឲ្យនោះ គឺវាសំខាន់ ហើយវាជួយកាត់បន្ថយការលំបាករបស់កម្មករ និងកម្មការិនីរោងចក្របានច្រើន ។

លោកស្រីបានបញ្ជាក់ថា "ធូរមែនទែនណាស់ មិនមែនលេងសើចទេ អាកើតកូន អាពិនិត្យសុខភាព អាពេលឈឺថ្កាត់អីនេះទៅពេទ្យអស់លុយច្រើនណាស់"។

នៅក្នុងឆ្នាំនេះ កម្ពុជាបានដំណើរការបោះឆ្នោតព្រឹទ្ធសភា រួចហើយកាលពីខែកុម្ភៈកន្លងទៅថ្មីៗនេះ ប៉ុន្តែកម្ពុជានៅមានការបោះឆ្នោតដ៏សំខាន់មួយទៀត នៅក្នុងថ្ងៃទី២៩ ខែកក្កដា ខាងមុខ។ ចាប់ពីពេលនេះរហូតដល់ ពេលបោះឆ្នោត គឺមានពេលមិនខ្លីទៀតនោះទេ។

បើតាមប្រសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានថ្លែងនៅពេលជួបកម្មករ និងកម្មការិនីរោងចក្រកាត់ដេរ សឹងតែរាល់សប្តាហ៍បានឲ្យដឹងថា ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល នៅក្នុងការផ្តល់កញ្ចប់សេវាកម្ម ជូនដល់កម្មករ និងកម្មការិនីរោង ចក្រកាត់ដេរទាំងអស់មិនមែនជារឿងដែលងាយស្រួល គឺសុទ្ធតែមានការពិគ្រោះយោបល់ច្បាស់លាស់ ហើយកំណត់ទុកនៅក្នុងគោលនយោបាយត្រឹមត្រូវ។

សម្តេចតេជោ ហ៊ុន សែន តែងតែបានថ្លែងថា រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់កម្រិតជីវភាព និងគាំពារដល់កម្មករ កម្មការិនី និងពលរដ្ឋកម្ពុជាទាំងអស់ តាមគោលនយោបាយមួយ ដ៏ជាក់លាក់៕

*ដោយ អរិយបុត្រ*



ថតដោយ: សហការី ស៊ីអេសស៊ី

# ការផ្សព្វផ្សាយ និងការប្រើប្រាស់គ្រឿងស្រវឹង មានការកើនឡើងគួរឲ្យបារម្ភ"



ថតដោយ: អរិយបុត្រ

ស្ទើរគ្រប់ដងវិថីធំៗ មិនថាតែនៅក្នុងទីក្រុង និងតាមបណ្ដាខេត្ត ផ្ទាំងប៉ាណូផ្សព្វផ្សាយស្រាបៀរ ឬគ្រឿងស្រវឹងបញ្ឈរជាជួរប្រណាំងជាមួយនឹងដើមឈើ និងគេហដ្ឋានរបស់ប្រជាពលរដ្ឋ។ នៅកម្ពុជា គ្រឿងស្រវឹងជាមូលហេតុចម្បងទី២ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងខាតបង់ថវិកាជាតិប្រមាណ៤៤លានដុល្លារក្នុងមួយឆ្នាំៗ។

យោងតាមលទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋស្ដីពីគ្រឿងស្រវឹង ដែលធ្វើឡើងនៅចុងឆ្នាំ២០១៤ ដោយសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមការគាំទ្ររបស់អង្គការសុខភាពពិភពលោក អង្គការចលនាដើម្បីសុខភាពកម្ពុជា និងដៃគូសុវត្ថិភាពចរាចរណ៍ផ្លូវគោកសកល ដោយបានរកឃើញថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនចាប់ផ្ដើមប្រើប្រាស់គ្រឿងស្រវឹង ក្នុងវ័យយុវជន និងកុមារមានរហូតទៅដល់៩១%។ លទ្ធផលនៃការស្ទង់មតិដដែលនេះ ក៏បានរកឃើញដែរថា ប្រជាពលរដ្ឋកម្ពុជារហូតទៅដល់៩៨% បានជួបប្រទះការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងតាមទម្រង់រូបភាពផ្សេងៗគ្នា ដូចជាផ្សាយពាណិជ្ជកម្មតាមទស្សនាវដ្ដី តាមសារព័ត៌មាន ស្ត្រីផ្សព្វផ្សាយស្រា ព្រឹត្តិការណ៍សង្គម ការប្រគុំតន្ត្រី តាមវិទ្យុ ផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា និងពិសេសហើយមានច្រើនជាងគេគឺតាមស្ប៉ត និងការប្រគុំតន្ត្រីតាមទូរទស្សន៍។

លោក គឹម សាញ់ មន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា បានឲ្យដឹងថា ការផ្សព្វផ្សាយគ្រឿងស្រវឹងនេះពិតជាមានការប៉ះពាល់ខ្លាំងណាស់ដល់យុវជនខ្លាំងណាស់ ដោយសារតែពួកគេស្ថិតក្នុងវ័យមួយ ដែលចង់ដឹង ចង់សាក ក្នុងវ័យរបស់ពួកគេគឺត្រូវការរៀនសូត្រ។

លោកបានបន្ថែមទៀតថា "ក្រសួងក៏បានធ្វើការងារជាច្រើនទាក់ទងនឹងការទប់ស្កាត់ចំពោះការប្រើប្រាស់គ្រឿងស្រវឹងក្នុងសាលារៀន។ ដោយក្នុងនោះក្រសួងក៏បានចេញជាលិខិតណែនាំទៅដល់គ្រប់សាលានៅទូទាំងប្រទេសមិនឲ្យមានការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងគ្រឹះស្ថានសិក្សា ហាមធ្វើការផ្សព្វផ្សាយគ្រឿងស្រវឹងនៅក្នុងគ្រឹះស្ថានសិក្សា ហើយយើងក៏ធ្វើការអប់រំដល់សិស្សានុសិស្សពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងផងដែរ"។

និស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ កញ្ញាសេង ណៃហួង បានឲ្យដឹងថា នាងឃើញថាការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងពិតជាប៉ះពាល់ខ្លាំងដល់យុវជនខ្មែរ ដោយសារតែធ្វើឱ្យអ្នកមើលចង់ប្រើហើយចង់សាកម្ដងហើយម្ដងទៀត។

យុវជនមួយរូបទៀត លោកសុងហ៊ុក៏បានពីការបារម្ភទាក់ទងនឹងការកើនឡើងនៃការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងកាន់តែច្រើនឡើងនេះដែរ។ លោកលើកឡើងថា ទោះបីមានការព្រមានជាច្រើនដងពីក្រសួងពាក់ព័ន្ធក្ដី ប៉ុន្តែការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនៅតែបន្តមានជាបន្តបន្ទាប់។

តាមរបាយការណ៍ស្ទង់មតិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញដដែលបានបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាពេញវ័យលើសពី ៥០% ធ្លាប់ទទួលទានគ្រឿងស្រវឹង ក្នុងនោះបុរសមានអត្រាខ្ពស់រហូតដល់ជាង ៧០%។ អត្រាដ៏ខ្ពស់នៃការប្រើប្រាស់គ្រឿងស្រវឹងនេះត្រូវបានអ្នកជំនាញរកឃើញថា បណ្ដាលមកពីការទាក់ទាញតាមរយៈការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា យ៉ាងអនាធិបតេយ្យ។

លោកវេជ្ជបណ្ឌិត មុំ គង់ នាយកប្រតិបត្តិអង្គការចលនាដើម្បីសុខភាពកម្ពុជា ក៏បានមានប្រសាសន៍ថា បច្ចុប្បន្នការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងកំពុងជះឥទ្ធិពលលើយុវជនខ្មែរ ដែលជាកង្វល់មួយសម្រាប់កម្ពុជា ដែលប្រទេសនេះមិនទាន់មានច្បាប់សម្រាប់គ្រប់គ្រងបញ្ហាទាំងនេះនៅឡើយ។ ប្រជាពលរដ្ឋកម្ពុជា៩៦% ស្នើសុំដល់រាជរដ្ឋាភិបាលឲ្យចាត់វិធានការដែលមានប្រសិទ្ធភាពបន្ថែមទៀតដើម្បីកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង។ ក្នុងន័យនេះការអនុម័តច្បាប់ស្ដីពីការគ្រប់គ្រងផលិតផលគ្រឿងស្រវឹង គឺជាវិធានការដ៏មានប្រសិទ្ធភាពបំផុត។

តាមសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងពាណិជ្ជកម្មគ្រឿងស្រវឹង ត្រូវបានរៀបចំឡើងតាំងពីឆ្នាំ២០១៥ ដោយរំពឹងថា នៅពេលដែរច្បាប់នេះ ចេញជាធរមាននឹងមានការដំឡើងពន្ធ និងវិធានការមួយចំនួនសម្រាប់កម្រិតដល់ការចរាចរផលិតផលគ្រឿងស្រវឹងនៅកម្ពុជា រួមនឹងវិធានការមួយចំនួនពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រា ៤១**

លក្ខខណ្ឌផ្សេងៗទាក់ទងនឹងបណ្ណនបើកបរ ត្រូវកំណត់ដូចខាងក្រោម ៖

**១.** អ្នកបើកបរម្នាក់មានសិទ្ធិកាន់បណ្ណបើកបរតែមួយគត់ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។ បណ្ណបើកបរត្រូវបានបែងចែកច្បាស់លាស់តាមប្រភេទយានយន្តដែលអ្នកបើកបរមានសិទ្ធិបើកបរ។ បណ្ណបើកបរនីមួយៗត្រូវប្រើប្រាស់ភ្ជាប់ជាមួយនូវបណ្ណពិន្ទុ។ បែបបទ និងនីតិវិធីនៃការចេញបណ្ណបើកបរ និងបណ្ណពិន្ទុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**២.** ជនពិការមានសិទ្ធិបើកបរយានយន្តពិសេសសម្រាប់តែជនពិការនិងលក្ខខណ្ឌនៃការចេញបណ្ណបើកបរសម្រាប់ជនពិការត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**៣.** អាយុអ្នកបើកបរត្រូវកំណត់តាមប្រភេទបណ្ណបើកបរ ដូចខាងក្រោម ៖

- អាយុ ១៦(ដប់ប្រាំមួយ) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ ក១
- អាយុ១៨ (ដប់ប្រាំបី) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ ក២ និង ខ
- អាយុ ២២ (ម្ភៃពីរ) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ គ និង ឃ១
- អាយុ ២៤ (ម្ភៃបួន) ឆ្នាំ យ៉ាងតិច ចំពោះ ប្រភេទ ឃ២ និង ង

**៤.** អ្នកមានបណ្ណប្រភេទ ក២ អាចបើកបរយានយន្តប្រភេទ ក១ បាន ។

**៥.** អ្នកមានបណ្ណបើកបរប្រភេទ ខ អាចបើកបរយានយន្តប្រភេទ ក១ យានយន្តកសិកម្ម ឬយានយន្ត។ ឧបករណ៍ដែលមានល្បឿនអតិបរមាមិនលើសពី ៤០ (សែសិប) គីឡូម៉ែត្រក្នុងមួយម៉ោង តែមិនអាចបើកបរយានយន្តប្រភេទផ្សេងទៀតបានទេ។

**៦.** ចំពោះអ្នកបើកបរយានយន្តដែលមានល្បឿនអតិបរមាលើសពី ៤០ (សែសិប) គីឡូម៉ែត្រក្នុងមួយម៉ោង ត្រូវមានបណ្ណបើកបរប្រភេទ គ ។

**៧.** ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ គ ត្រូវមានបណ្ណបើកបរប្រភេទ ខ ឬ ឃ១ សិន ។

**៨.** អ្នកបើកបរយានយន្តប្រភេទ គ ឬ ឃ អាចបើកបរយានយន្តប្រភេទ ខ បាន ។

**៩.** អ្នកមានបណ្ណបើកបរប្រភេទ គ មិនអាចបើកបរយានយន្តប្រភេទ ឃ២ បានទេ ប៉ុន្តែអ្នកមានបណ្ណបើកបរប្រភេទ ឃ២ អាចបើកបរយានយន្តប្រភេទ ខ ឬ គ ឬ ឃ១ បាន។

**១០.** ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ ឃ១ ត្រូវមានបណ្ណបើកបរប្រភេទ ខ សិន។

**១១.** ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ ឃ២ ត្រូវមានបណ្ណបើកបរប្រភេទ ខ ឬ គ ឬ ឃ១សិន។

**១២.** ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ ង ត្រូវមានបណ្ណបើកបរប្រភេទ ខ ឬ គ ឬ ឃ សិន។

**១៣.** អ្នកមានបណ្ណបើកបរប្រភេទងអាចមានសិទ្ធិបើកបររថយន្តសណ្ដោងរ៉ឺម៉ក ដែលមានទម្ងន់អតិបរមាលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោនបានទៅតាមប្រភេទបណ្ណបើកបរដូចជា ង (ខ) ឬ ង (គ) ឬ ង (ឃ)។

(មានតនៅលេខក្រោយ)

# កិច្ចប្រជុំកំពូលនៃមហាអនុតំបន់ទន្លេមេគង្គគឺផ្តួចផ្តើមដោយកម្ពុជា

ថ្មីៗនេះ មេដឹកនាំប្រទេស៦ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គបានចូលរួមកិច្ចប្រជុំកំពូលនៃមហាអនុតំបន់ទន្លេមេគង្គ នៅទីក្រុងហាណូយប្រទេសវៀតណាម ប៉ុន្តែតើមានដឹងទេថា កិច្ចប្រជុំនេះប្រទេសណាជាអ្នកផ្តួចផ្តើម ហើយតើវាបង្កើតឡើងដើម្បីអ្វី តើវាមានសារៈសំខាន់យ៉ាងណាសម្រាប់ប្រទេសដែលជាសមាជិកនៃកិច្ចប្រជុំនេះ។

កិច្ចប្រជុំកំពូលនេះ គឺជាទូទៅបានរៀបចំនៅក្នុងរង្វង់៣ ឆ្នាំម្តង ហើយវាគឺជាវេទិការក្នុងកម្រិតខ្ពស់ បំផុតនៅក្នុងកម្មវិធីនៃមហាអនុតំបន់ទន្លេមេគង្គ ដែលចុងបញ្ចប់នៃកិច្ចប្រជុំ គឺតែងតែមាននូវ សេចក្តីប្រកាសព័ត៌មាន ដែលចុះហត្ថលេខាដោយមេដឹកនាំដែលចូលរួមប្រជុំ។ កិច្ចប្រជុំនេះ គឺជាឱកាសមួយ ដែលមេដឹកនាំតំបន់ ដែលរួមមានកម្ពុជា ឡាវ វៀតណាម ថៃ ភូមា និងចិន មានឱកាសនៅក្នុងការត្រួតពិនិត្យមើល និន្នាការសាកលលោក គឺវាកំពុងតែផ្តល់ផលប៉ះពាល់យ៉ាងណា ដល់មហាអនុតំបន់នេះ ក៏ដូចជារៀបចំផែនការផ្សេងៗ នៅក្នុងការធ្វើសហប្រតិបត្តិការ និងជំរុញសមាហរណកម្ម ហើយក៏ដូចជាពិនិត្យ និងស្វែងរកនូវយុទ្ធសាស្ត្រ សម្រាប់ជំរុញដំណើរការអភិវឌ្ឍន៍។

គោលគំនិតដ៏ចម្បងមួយទៀត គឺមេដឹកនាំតំបន់ គឺមានបំណងនឹងប្រែក្លាយកិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំពិសេស ដើម្បីជំរុញពិពិធកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ដើម្បីព្យាយាមយ៉ាងណា លុបបំបាត់គម្លាតនៃការអភិវឌ្ឍន៍រវាងសមាជិកអាស៊ានទាំងអស់ ពីព្រោះសមាជិកទាំងអស់នៃកិច្ចប្រជុំនេះ គឺមានតែចិនមួយទេ ដែលមិនមែនជាសមាជិកអាស៊ាន ប៉ុន្តែជាដៃគូ។ បណ្តាប្រទេសសមាជិកទាំងនោះ គឺជាសមាជិកអាស៊ានថ្មី លើកលែងតែថៃ ដែលមានធនធានមនុស្ស មានធនធានសក្តានុពលសេដ្ឋកិច្ចពិសេសគឺ ការអភិវឌ្ឍនៅក្រោយអាស៊ានផ្សេងទៀតដែលមាន សិង្ហបុរី ម៉ាឡេស៊ី ថៃ ប្រុយណេ ហ្វីលីពីន និងឥណ្ឌូនេស៊ី។

កិច្ចប្រជុំកំពូលនៃមហាអនុតំបន់ទន្លេមេគង្គ លើកទីមួយត្រូវបានគេដឹងថា បានរៀបចំឡើងនៅកម្ពុជា នៅក្នុងឆ្នាំ២០០២ បន្ទាប់មកនៅចិននាឆ្នាំ២០០៥ ហើយបានបន្តមកឡាវ នៅក្នុងឆ្នាំ២០០៨ និងភូមា នៅឆ្នាំ២០១១ បន្តមកថៃ នៅឆ្នាំ២០១៤ និងនៅវៀតណាមនាឆ្នាំ២០១៨ ពោលគឺនៅហាណូយ កាលពីថ្ងៃទី៣០ ដល់៣១ ខែមីនា កន្លងទៅនេះ ដែលប្រមុខរដ្ឋាភិបាលកម្ពុជា បានទៅចូលរួម។

នៅរៀងរាល់កិច្ចប្រជុំកំពូលម្តងៗ ក្រៅពីមេដឹកនាំប្រទេសទាំង៦ កិច្ចប្រជុំនេះក៏បានទាក់ទាញការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍផ្សេងៗដូចជា អគ្គលេខាធិការអាស៊ាន តំណាងធនាគារពិភពលោក តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ផងដែរ ហើយមកដល់ពេលនេះ ធនាគារនេះ គឺជាដៃគូអភិវឌ្ឍន៍ដ៏ធំសម្រាប់តំបន់។ ដោយឡែកនៅក្នុងឆ្នាំនេះ ប្រធានធនាគារអភិវឌ្ឍន៍អាស៊ីបានអបអរសាទរមហាអនុតំបន់ទន្លេមេគង្គ ក្នុងឱកាសខួបលើកទី ២៥ ឆ្នាំនៃកិច្ចសហប្រតិបត្តិការរវាង មហាអនុតំបន់នេះ និងធនាគារនេះ។

លោក តាកេហ៊ីកូ ណាខាអូ ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី បានសម្តែងនូវការអបអរសាទរចំពោះប្រទេស ជាសមាជិកទាំង៦។ លោកបានគូសបញ្ជាក់សាជាថ្មីពីការបន្តផ្តល់ការគាំទ្ររបស់ធនាគារ ដល់កម្មវិធីនេះ ក្នុងថវិកា ៧ ពាន់លានដុល្លារ ក្នុងរយៈពេល ៥ឆ្នាំទៀត ដើម្បីជួយឱ្យអនុតំបន់នេះសម្រេចនូវកំណើនបរិយាបន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងសុន្ទរកថាទៅកាន់កិច្ចប្រជុំកំពូលនៃមហាអនុតំបន់ទន្លេមេគង្គ និងកិច្ចប្រជុំកំពូលធុរកិច្ចនៅមហាអនុតំបន់ទន្លេមេគង្គ លោក តាកេហ៊ីកូ ណាខាអូ បានមានប្រសាសន៍ថា "ខ្ញុំសូមវាយតម្លៃខ្ពស់ដល់ប្រទេសមហាអនុតំបន់ទាំងអស់ ចំពោះសមិទ្ធផលសម្រេចបានពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ"។ កម្មវិធីមហាអនុតំបន់ត្រូវបានផ្តួចផ្តើមបង្កើតឡើង ក្នុងខែតុលា ឆ្នាំ១៩៩២ ដោយធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ការគាំទ្រជាលេខាធិការដ្ឋាន ដើម្បីជួយដល់ដំណើរការអន្តរកាល និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ តាមរយៈការលើកទឹកចិត្តឱ្យមានទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មឆ្លងដែន។

លោក តាកេហ៊ីកូ ណាខាអូ បានមានប្រសាសន៍ថា "បច្ចុប្បន្ននេះ ប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ គឺជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័សជាងគេនៅអាស៊ី និងក្នុងពិភពលោក"។ "ប្រទេសទាំងនេះ បានទទួលស្គាល់ពីអត្ថប្រយោជន៍នៃសមាហរណកម្មថ្នាក់តំបន់ និងការតភ្ជាប់ទំនាក់ទំនងជាមួយប្រទេសដទៃទៀតក្នុងសកលលោកទាំងមូល។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងបន្តសម្របសម្រួលកម្មវិធី មហាអនុតំបន់នេះឈរលើមូលដ្ឋាននៃការជឿទុកចិត្តគ្នាទៅវិញទៅមក និងអក្សរ CCC ដែលតំណាងឱ្យការតភ្ជាប់ទំនាក់ទំនង ភាពប្រកួតប្រជែង និងសហគម។

កម្មវិធីមហាអនុតំបន់ បានគាំទ្រដល់គម្រោងជាច្រើន ដែលមានតម្លៃស្មើនឹង ២១ពាន់លានដុល្លារ ចាប់តាំងពីកម្មវិធីនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩២ មកក្នុងវិស័យផ្សេងៗ ដូចជាគមនាគមន៍ ទេសចរណ៍ សុខាភិបាល ការអភិវឌ្ឍទីក្រុង បរិស្ថាន ការអភិវឌ្ឍធនធានមនុស្ស កសិកម្ម និងថាមពល។ ថវិកាប្រមាណ ៤០% នៃហិរញ្ញប្បទានសម្រាប់គម្រោងទាំងនេះ មានប្រភពពី ADB ២៥% ពីរដ្ឋាភិបាលក្នុងប្រទេសជាសមាជិក មហាអនុតំបន់ និងថវិកាដែលនៅសល់ផ្សេងទៀត បានពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី។ កម្មវិធីដែលអនុវត្តក្នុងប្រទេស មហាអនុតំបន់និមួយៗ ត្រូវបានរៀបចំឡើងឱ្យស្របទៅតាមបរិបទពិសេសរបស់ប្រទេសនោះ។

ផ្អែកទៅតាមផែនការសកម្មភាពទីក្រុងហាណូយ និងក្របខណ្ឌវិនិយោគថ្នាក់តំបន់ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំកំពូលមហាអនុតំបន់ នៅហាណូយ នឹងផ្តល់ការគាំទ្រដល់គម្រោងចំនួន ២២៧ដែលមានតម្លៃ ៦៦ពាន់លានដុល្លារ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ដែលក្នុងនោះធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់ហិរញ្ញប្បទានប្រមាណ ៧ពាន់លានដុល្លារ។ ផែនការនេះអំពាវនាវឱ្យមានការពង្រីកច្រករបៀងសេដ្ឋកិច្ច ដើម្បីជំរុញការតភ្ជាប់ទំនាក់ទំនងរវាងប្រទេសនានា ព្រមទាំងទំនាក់ទំនងរវាងតំបន់ជនបទ និងតំបន់ប្រជុំជន ដើម្បីធានាឱ្យមានការបែងចែកអត្ថប្រយោជន៍ដែលបានកំណើនសេដ្ឋកិច្ច ឱ្យកាន់តែមានសមធម៌បន្ថែមទៀត៕ *ដោយ អរិយបុត្រ*



# ឥណ្ឌាប្រកាសដកច្បាប់ស្តីពីព័ត៌មានក្លែងក្លាយ ក្រោយប្រកាសមិនដល់២៤ម៉ោង

នាយករដ្ឋមន្ត្រីឥណ្ឌា លោក ណារេន ដ្រាម៉ូឌី កាលពីថ្ងៃអង្គារ ទី៣ ខែមេសា បានបញ្ជាឲ្យដកចេញច្បាប់ដាក់ទោសអ្នកសារព័ត៌មាន ដែលទទួលខុសត្រូវចំពោះការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ បន្ទាប់ពីប្រកាសបានមិនដល់២៤ម៉ោងផង។

ចំណាត់ការដកចេញវិញនេះធ្វើឡើងបន្ទាប់ពីផ្ទុះកំហឹង និងការរិះគន់ពីអ្នកកាសែត និងអ្នកនយោបាយប្រឆាំង ដែលថាច្បាប់នេះតំណាងឲ្យការវាយប្រហារលើសេរីភាពសារព័ត៌មាន និងជាកិច្ចខិតខំមួយដោយរដ្ឋាភិបាលរបស់លោកម៉ូឌីដើម្បីខ្ទប់ការបញ្ចេញមតិដោយសេរីនៅមុនការបោះឆ្នោតសកលមួយនៅឆ្នាំក្រោយ។

កាលពីយប់ថ្ងៃចន្ទ ក្រសួងព័ត៌មាន និងការផ្សព្វផ្សាយឥណ្ឌាបាននិយាយថា រដ្ឋាភិបាលនឹងលុបចោលសិទ្ធិអនុញ្ញាតសម្រាប់អ្នកកាសែតណា ដែលផ្សព្វផ្សាយ "ព័ត៌មានក្លែងក្លាយ" ដូចជាមិនអនុញ្ញាតឲ្យចូលជួបសម្ភាសន៍មន្ត្រីរដ្ឋាភិបាល ឬមិនអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទកាសែត និងសិក្ខាសាលាដែលរៀបចំឡើងដោយស្ថាប័នរដ្ឋ តែមិនបាននិយាយដល់ទោសព្រហ្មទណ្ឌដាក់គុកដាក់ច្រវាក់ទេ។ តែក្រោយអន្តរាគមន៍ពីនាយករដ្ឋមន្ត្រី ក្រសួងបានប្រកាសលុបចោលវិញ។

ពួកអ្នកកាសែតបានស្វាគមន៍ការដកចេញវិញនេះ តែថា វាអាចជាធ្វើតេស្តមួយដើម្បីដាក់ការកំហិតបន្ថែមទៀតលើសារព័ត៌មាន។

ហេតុការណ៍នៅឥណ្ឌាបានកើតមានបន្ទាប់ពីម៉ាឡេស៊ីអនុម័តច្បាប់ប្រឆាំងព័ត៌មានក្លែងក្លាយ ដោយអ្នករំលោភអាចជាប់គុក៦ឆ្នាំ ឬពិន័យជាប្រាក់ ឬទាំងពីរ។

ប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ មានសិង្ហបុរី និងហ្វីលីពីន ក៏កំពុងពិចារណារកវិធីដោះស្រាយព័ត៌មានក្លែងក្លាយនេះដែរ តែពួកសកម្មជនសិទ្ធិមនុស្សខ្លាចក្រែងច្បាប់នេះត្រូវគេយកទៅប្រើដើម្បីខ្ទប់ការបញ្ចេញមតិដោយសេរី៕

# ចិន និងអាមេរិកកំពុងបញ្ឆេះសង្គ្រាមពាណិជ្ជកម្មហើយ

កាលពីថ្ងៃពុធទី៤ ខែមេសា អាជ្ញាធរចិនបានប្តេជ្ញាដាក់វិធានការតាមកម្លាំងដូចគ្នា ដើម្បីជាការឆ្លើយតបទៅនឹងការដំឡើងពន្ធលើទំនិញចិនតំលៃ៥០ពាន់លានដុល្លារ នៅក្នុងជម្លោះបច្ចេកវិទ្យាមួយដែលនាំឲ្យមានការព្រួយបារម្ភខ្លាចក្រែងវាទាញកំណើនសេដ្ឋកិច្ចពិភពលោកឲ្យថយក្រោយវិញ ដើម្បីឆ្លើយតបនឹងអាមេរិក។

ក្រសួងពាណិជ្ជកម្មចិនបាននិយាយថា ខ្លួននឹងតវ៉ានឹងចំណាត់ការរបស់អាមេរិកនេះភ្លាម នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក(WTO)។

ក្រសួងពាណិជ្ជកម្មចិនបាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា "ក្នុងពេលជាមួយគ្នា យើងចាត់វិធានការក្នុងកម្លាំងស្មើគ្នា និងទំហំដូចគ្នាប្រឆាំងទំនិញអាមេរិក។ វិធានការទាំងនេះនឹងត្រូវប្រកាសក្នុងពេលឆាប់ៗ"។

ប្រតិកម្មភ្លាមៗរបស់ចិនកើតឡើងមួយថ្ងៃបន្ទាប់ពីអាមេរិកបញ្ចេញតារាងដាក់ពន្ធលើទំនិញនាំចូល១.៣០០មុខរបស់ចិន។

ការិយាល័យតំណាងពាណិជ្ជកម្មអាមេរិក(USTR) បាននិយាយនៅក្នុងសេចក្តីប្រកាសព័ត៌មានមួយថា សហរដ្ឋអាមេរិកនឹងកំណត់ពន្ធបន្ថែមលើផលិតផលនាំចូលពីប្រទេសចិន ដោយសរុបជិត១.៣០០មុខដោយរួមទាំងផលិតផលដែលផលិតដោយឧស្សាហកម្មផលិតគ្រឿងអាកាសចរណ៍ និងបច្ចេកវិទ្យាព័ត៌មានរបស់ប្រទេសចិន។

សេចក្តីប្រកាសព័ត៌មាននេះ បាននិយាយកាលពីថ្ងៃអង្គារ ទី៣ ខែមេសាថា បញ្ជីផលិតផលត្រូវបានស្នើឡើងនេះ គឺផ្អែកលើការវិភាគសេដ្ឋកិច្ចដ៏ទូលំទូលាយហើយនឹងផ្តោតលើផលិតផលដែលទទួលបាន ផលប្រយោជន៍ពីផែនការឧស្សាហកម្មរបស់ចិន ដើម្បីកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ចអាមេរិក ឬនិយាយឲ្យចំគឺបន្ថយគម្លាតឱនភាពពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ ពួកមន្ត្រីចិនមិនបានផ្តល់សញ្ញាថា តើទំនិញអាមេរិកអ្វីអាចជាគោលដៅវាយពន្ធសងសឹក តែពួកអ្នកជំនួញ និងអ្នកសេដ្ឋកិច្ចបាននិយាយថា យន្តហោះធំៗ និងសណ្តែកសៀងអាចជាគោលដៅ។

ក្រុមហ៊ុនអាមេរិកមួយចំនួនបានព្រមានថា ចំណាត់ការរបស់លោកប្រធានាធិបតីត្រាំ ដែលបង្កឡើងមុនប្រឆាំងចិនអាចប៉ះពាល់បណ្តាក្រុមហ៊ុន និងអ្នកប្រើប្រាស់អាមេរិក ខណៈចិនប្តេជ្ញាចាត់វិធានការ "កម្លាំងស្មើគ្នា" ក្រោយអាមេរិកបញ្ចេញតារាងដាក់ពន្ធលើទំនិញ១.៣០០មុខរបស់ចិន៕

# នាយករដ្ឋមន្ត្រីម៉ាឡេស៊ី សន្យាដំឡើងប្រាក់ខែជូនមន្ត្រីរដ្ឋការនៅមុនការបោះឆ្នោត

នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ណាជីប រ៉ាហ្សាក់ កាលពីថ្ងៃពុធ ទី៤ ខែមេសា បានសន្យាបញ្ចេញប្រាក់១.៤៦០លានរីងហ្គីត ឬប្រមាណជា ៣៧៨,០៤លានដុល្លារ នៅក្នុងមួយឆ្នាំ សម្រាប់ដំឡើងប្រាក់ខែដល់មន្ត្រីរដ្ឋការស៊ីវិល។

បុគ្គលិក និងមន្ត្រីរដ្ឋការស៊ីវិលរបស់ម៉ាឡេស៊ី១,៦លាននាក់ ភាគច្រើនជាជនជាតិម៉ាឡេ តែងតែជាអ្នកគាំទ្រក្រុមចំរុះជាតិបារីសាន់ដែលកំពុងកាន់អំណាច ប៉ុន្តែថ្លៃទ្រទ្រង់ការរស់នៅកើនឡើងបានក្លាយជាការព្រួយបារម្ភសម្រាប់មនុស្សជាច្រើន ដោយមន្ត្រីបក្សកាន់អំណាចខ្លះព្រមានថា ពួកគេអាចងាកមកប្រឆាំងបក្សវិញ ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយ។

ចំណែកលោកណាជីប ដែលរួបរឹតដោយរឿងអាស្រូវហិរញ្ញវត្ថុត្រូវការគាំទ្ររួមគ្នា ដើម្បីក្រុមចម្រុះរបស់លោកគេចផុតការប្រជែងដ៏ខ្លាំងពីអតីតនាយករដ្ឋមន្ត្រីក្លាយជាមេដឹកនាំប្រឆាំងលោក មហាធៀ ម៉ូហាម៉ាត។

លោក ណាជីប បានប្រាប់ការជួបជុំបុគ្គលិកមន្ត្រីរដ្ឋការស៊ីវិលមួយនៅរដ្ឋធានី ពូត្រាចាយ៉ាថា "រដ្ឋាភិបាលបានយល់ព្រមបង្កើនប្រាក់ខែដល់មន្ត្រីរដ្ឋការស៊ីវិលទាំង១,៦លាននាក់...ជាមួយប្រាក់បន្ថែម១.៥៦០លានរីងហ្គីត ចាប់ពីថ្ងៃ១ ខែកក្កដាទៅ"។

សូមបញ្ជាក់ថា នៅមុនការបោះឆ្នោតឆ្នាំ២០១២ បុគ្គលិកមន្ត្រីរដ្ឋការស៊ីវិលម៉ាឡេស៊ី ក៏ទទួលបានការដំឡើងប្រាក់ខែផងដែរពីចន្លោះ៧ទៅ១៣ភាគរយ៕

# អាស៊ានបីប្រទេសស្ថិតនៅក្នុងចំណោមមហាអំណាចយោធាទាំង២០នៅលើពិភពលោក

សេចក្តីរាយការណ៍ព័ត៌មានបរទេសមួយបានអះអាងថា ប្រទេសអាស៊ានចំនួនបី ដែលរួមមាន ឥណ្ឌូនេស៊ី វៀតណាម ថៃ គឺស្ថិតនៅក្នុងចំណោមប្រទេសដែលមានកងទ័ពខ្លាំងបំផុតទាំង២០ នៅក្នុងចំណោមប្រទេស ១៣៣ នៅលើពិភពលោក។

សេចក្តីរាយការណ៍ដដែលលេខ៣ ហើយប្រទេសអាស៊ីផ្សេងទៀត ដែលឈរនៅក្នុងចំណោមប្រទេសដែលមានយោធាខ្លាំងទាំង២០ គឺមានដូចជា ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង ប៉ាគីស្ថាន និងកោះតៃវ៉ាន់ផងដែរ។ កងកម្លាំងប្រដាប់អាវុធចំនួន ១៣៣ ដោយផ្អែកលើសមត្ថភាពរបស់ពួកគេលើដីគោកអាកាសនិងសមុទ្រក៏ដូចជាសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធសព្វាវុធផ្សេងៗ។ ចិនមានយន្តហោះ និងនាវាចម្បាំងច្រើនជាងរុស្ស៊ី ប៉ុន្តែមានរថក្រោះតិចជាងរុស្ស៊ីឆ្ងាយណាស់។ កងកម្លាំងប្រដាប់អាវុធចិនទទួលបានពិន្ទុ ០,០៩៤ និងត្រូវបាននាំមុខដោយរុស្ស៊ី និងសហរដ្ឋអាមេរិក។

ខណៈដែលសហរដ្ឋអាមេរិកមានកងទ័ពខ្លាំងជាងគេនៅលើពិភពលោកជាមួយនឹងបច្ចេកវិជ្ជាទំនើបៗ និងកម្លាំងទ័ពទទួលការបណ្តុះបណ្តាលយ៉ាងខ្លាំងក្លានោះ។

ឥណ្ឌាបានរក្សាជំហររបស់ខ្លួនក្នុងចំណោមមហាអំណាចយោធាកំពូលទាំង៥ នៅលើពិភពលោកក្នុងបញ្ជី។ ប្រទេសឥណ្ឌានាំមុខចិនទាក់ទងទៅនឹងចំនួនកងកម្លាំងប្រដាប់អាវុធ ដែលមានចំនួនសរុបចំនួន ៤.២០៧.២៥០នាក់ ទល់នឹងទាហានចិនចំនួន ៣.៧១២.៥០០នាក់។

ទោះយ៉ាងណា ប្រទេសចិននាំមុខខាងទាហានសកម្មដែលមានចំនួន ២.២៦០.០០០នាក់ ធៀបនឹងឥណ្ឌាមានចំនួន ១.៣៦២.៥០០នាក់។

ជប៉ុនជាប់ចំណាត់ថ្នាក់លេខ៧ នៅទូទាំងពិភពលោក ទោះបីជាយោធាជប៉ុនតូច ប៉ុន្តែយោធាជប៉ុនមានប្រព័ន្ធអាវុធទំនើបៗ មានថវិកាការពារជាតិគ្រប់គ្រងដោយនិរន្តភាព ប្រទេសនេះបានពង្រឹងអំណាចកងកម្លាំងដែនអាកាស ដែនទឹក និងដីគោក។

កូរ៉េខាងត្បូងជាប់ចំណាត់ថ្នាក់លេខ១២ នៅលើពិភពលោក ខណៈប្រទេសនេះកំពុងប្រឈមមុខនឹងការគំរាមកំហែងឈ្លានពានពីកូរ៉េខាងជើង និងបានពង្រឹងកងកម្លាំងយោធារបស់ខ្លួនលើគ្រប់ផ្នែក។

ប៉ាគីស្ថានជាប់ចំណាត់ថ្នាក់លេខ១៣ បន្ទាប់មក គឺប្រទេសឥណ្ឌូណេស៊ីជាប់ចំណាត់ថ្នាក់លេខ១៤ វៀតណាមជាប់ចំណាត់ថ្នាក់លេខ១៦ កោះតៃវ៉ាន់ជាប់ចំណាត់ថ្នាក់លេខ១៨ ប្រទេសថៃជាប់ចំណាត់ថ្នាក់លេខ២០៕

# ស្វែងយល់មតិពលរដ្ឋ ជុំវិញករណីអ្នកពាក់

វិវាទនៅលើទ្រូងផ្លូវ ដែលបង្កឡើងដោយគ្រោះថ្នាក់ចរាចរណ៍ នៅទូទាំងប្រទេសនៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជាជាបន្តបន្ទាប់ហើយករណីអ្នកពាក់-ព័ន្ធនឹងគ្រោះថ្នាក់នេះ មិនសូវចូលចិត្តឈប់ដោះស្រាយរហូតមកដល់បច្ចុប្បន្ន នៅតែមានជាច្រើនករណី បើទោះបីជាពេលនេះកម្ពុជាមានច្បាប់ចរាចរណ៍ផ្លូវគោកជាគោលក៏ដោយ ដូច្នេះតើនេះវាបណ្ដាលមកពីបញ្ហាអ្វី? សូមស្វែងយល់ការចូលរួមជាមតិយោ-បល់របស់បងប្អូនប្រជាពលរដ្ឋកម្ពុជា ដែលអ្នកនាំសារបានសម្ភាសន៍!



លោក បុត្រ បញ្ញាវ័ន្ត ជាអាជីវករមួយរូប ដែលមានអាយុ ២៩ឆ្នាំ បានចូលរួមបញ្ចេញជាយោបល់ថា តាមការសង្កេតករណីគ្រោះថ្នាក់ចរាចរណ៍នេះ បើសិនជាករណីអ្នកបើកបរម៉ូតូប៉ះជាមួយនឹងរថយន្ត គឺច្រើនតែថា ភាគីខាងរថយន្តខុសតែម្ដង ហើយម្នាក់ៗច្រើនតែដាក់បន្ទុកទៅលើអ្នកបើកបររថយន្ត បើទោះបីជាធាតុពិត អ្នកដែលរងគ្រោះ សន្លប់ ឬបាត់បង់ជីវិតនោះទេ ជាអ្នកបង្កក្ដី ដូច្នេះហើយបានជាអ្នកបើកបររថយន្តភាគច្រើន មិនសូវជាចូលចិត្តឈប់ដោះស្រាយនោះទេ។

លោកបានបន្តទៀតថា លោកធ្លាប់ឃើញហេតុការណ៍កើតឡើងនៅលើទ្រូងផ្លូវមួយកន្លែង តែមិនចាំពេលវេលាច្បាស់លាស់ទេ ដោយសារតែវាយូរដែរហើយ។ លោកបានរៀបរាប់ថា កាលនោះរថយន្តដូចជា ស៊ីញ៉ូបទត្រឹមត្រូវ នៅលើចំណែកផ្លូវរបស់គេ ប៉ុន្តែម៉ូតូគាត់មិនដឹងជិះយ៉ាងម៉េចទេ ជិះដែងគេដែងឯង ដែងទាំងលោកថែមទៀត ក៏ជ្រុលទៅប៉ះឡានមួយគ្រឿង ដួលបែកមុខបែកមាត់ តែងើបឡើងទៅទារឲ្យអ្នកបើកបររថយន្តសងទៀត ។

លោកបានបន្តទៀតថា នៅក្នុងពេលនោះ បើតាមលោកចាំ គឺដំបូងដូចជា គាត់ប្រុងសូមទោសគេដែរ ប៉ុន្តែមិនដឹងយ៉ាងម៉េចទេ ដោយកាលនោះ មានអ្នកមិនដឹងរឿងជាច្រើនមកបន្ទរ អ្នកបង្កក៏ដូចជាបានចិត្ត ក៏តាំងទាមទារឲ្យគេសងម៉ូតូ ហើយចេញថ្លៃថ្នាំឲ្យថែមទៀត ប៉ុន្តែសំណាងហើយ កាលនោះប៉ះអ្នកបើកបររថយន្តនោះគាត់ខ្ជិលមានរឿងវែងឆ្ងាយក៏ហូតលុយមួយចំនួនឲ្យ រឿងក៏ចប់ទៅ។

លោក បញ្ញាវ័ន្ត បានបញ្ជាក់ថា " រឿងវាអីចឹង បានជាអ្នកបើកបរឡាន (រថយន្ត) ភាគច្រើនឲ្យតែជួបគ្រោះថ្នាក់ចរាចរណ៍ តែងតែខ្ជិលឈប់។ ឲ្យគាត់ឈប់ម៉េច បើគាត់អស់ទាំងលុយជួសជុលឡានខ្លួនឯង ហើយ ជួយចេញថ្នាំពេទ្យឲ្យ អ្នកបង្កទៀត ហើយមិនស្រួលមានរឿងមានរ៉ាវពិបាកបកស្រាយ ថែមទៀតក៏ថាបាន"។

លោក លី ម៉េងឃន ជាប្រជាពលរដ្ឋវ័យ ៥៥ឆ្នាំមួយរូប បានចូលរួមបញ្ចេញយោ-បល់ថា អ្នកខ្លះដូចយកគ្រោះថ្នាក់ចរាចរណ៍នេះ មកធ្វើជារបររកស៊ីតែម្ដង។ លោកបានបន្តថា វាដូចជាមិនទំនងទេ ដោយសារតែលោកបានធ្លាប់ឃើញហេតុការណ៍គ្រោះ-ថ្នាក់ចរាចណ៍ ពីរឬបីករណីហើយ។ លោកបានបន្តទៀតថា វាដូចជាម៉េចទេ ដោយឡានគេបើកសុខៗ ក៏មានអ្នកដែលជិះម៉ូតូទៅប៉ះឡានគេ ហើយក៏ដួលម៉ូតូនោះ សន្លប់ស្រាប់តែមានមនុស្សពីរបីម៉ូតូផ្សេងទៀតមកដល់ជួយរឺតជួយប្រាប់ក៏ដឹងខ្លួន ហើយក៏តាំងសម្លុតអ្នកបើកបរ ចោទអ្នកបើកបរ ថាខុសអីចេះខុសអីចុះ ដើម្បីទារសំណង។

លោកបានបញ្ជាក់ថា "ខ្ញុំឃើញពីរបីដងដែរ អាករណីបែបនេះ នោះហើយសុទ្ធតែជាបច្ច័យដែលនាំឲ្យ អ្នកបើកបរដែលជួបគ្រោះថ្នាក់ចរាចរណ៍ រមែងតែបិតគូទសាប៊ូ( បើករត់ )"។

លោក គាវ គឿន ជាអ្នករត់ម៉ូតូឌុបមួយរូប បានឲ្យដឹងថា នៅក្នុងអាជីពជាអ្នករត់ម៉ូតូឌុបនៅទីក្រុងនេះ លោកធ្លាប់ជួបហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះច្រើនដងដែរ ប៉ុន្តែមិនដែលមានរឿងរ៉ាវអីធំដុំនោះទេ សំខាន់ឲ្យតែយើងចេះសូមទោសដឹងខុសដឹងត្រូវ។ លោកគឿន ដែលមានវ័យ ៣៣ឆ្នាំ បានអះអាងថា លោករត់ម៉ូតូឌុបនេះតាំងពីអាយុ១៩ឆ្នាំ ហើយធ្លាប់ជួបគ្រោះថ្នាក់ចរាចរណ៍ គេបុកលោក លោកបុកគេ ប៉ះឡានគេ ឡានគេបុក ប៉ុន្តែមិនដែលមាន គ្រោះថ្នាក់ធំដុំឡើយ គ្រាន់តែដាច់រលាត់ជើង អស់ជង្គង់ ហើយធ្លាប់ជួយចេញថ្លៃថ្នាំពេទ្យគេម្ដងពីរដែរ។

លោកបានបន្តថា កាលពី២ ឬ៣ ឆ្នាំមុន លោកធ្លាប់ឡានគា ដួលរយៈជើងដែរ ៤ ទៅ៥ថ្ងៃដែរ ហើយកាលនោះ ឡានក៏មិនបានឈប់មើលលោកដែរ។

លោកបានបន្តថា កាលនោះនៅលើផ្លូវជាតិលេខ១ លោកគេចឆ្វេក៏ទៅប៉ះត្រចៀកឡាន (កញ្ចក់ចំហៀងឡាន) ដួលម្នាក់ឯង បានអ្នកដំណើរ និងអ្នកភូមិចេញមកជួយគក់ប្របាច់ និងនាំទៅពេទ្យ។

លោកបានបន្តទៀតថា "កាលនោះឡានបើកលឿនបើតាមក៏មិនដឹងតាមយ៉ាងម៉េចដែរ ហើយណាមួយ លោកក៏មិនចំណាំឡានទៀត"។ លោកបានបន្តទៀតថា ដោយឡែកនៅក្នុងទីក្រុង លោកមិនដែលបានប៉ះករណីបែបនេះទេ ដោយរាល់ពេលដែលលោកប៉ះគេ ឬគេប៉ះ គឺសុទ្ធតែប៉ះអ្នកបើកបរដែលគាត់ចេញយល់យោគ។

## ប្រមុខរាជរដ្ឋាភិបាលជំរុញឲ្យចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងប្រើហិង្សាក្នុងករណីគ្រោះថ្នាក់ចរាចរណ៍

សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថ្កោលទោសជនបង្កហិង្សាក្នុងករណីគ្រោះថ្នាក់ចរាចរណ៍យ៉ាងមុឹងម៉ាត់បំផុត ។

សម្ដេច ហ៊ុន សែន ចាត់ទុកទង្វើប្រើហិង្សាលើអ្នកបើកបរក្រៅប្រព័ន្ធច្បាប់ថា ជារូបភាពឃោរឃៅ ដែលមិនគួរគប្បីកើតមាននៅកម្ពុជានោះទេ ព្រោះវាមិនមែនជាសីលធ៌មរបស់មនុស្សនោះទេ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានស្នើឲ្យសមត្ថកិច្ចបន្តចាប់ខ្លួនជនទាំងនោះ ដោយមិនត្រូវឲ្យជនពាលបែបនេះបង្កើតនូវស្ថានភាពបែបនេះហើយខ្វះការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌនោះទេ។

សម្ដេចតេជោបានបញ្ជាក់ថា "ខ្ញុំសូមយកឱកាសនេះ អំពាវនាវចំពោះប្រជាពល-រដ្ឋរបស់យើង ហិង្សា ដែលបានកើតឡើង ទាក់ទិននិងបញ្ហាគ្រោះថ្នាក់ចរាចរមិនមែនជារឿងដែលត្រូវស្វាគមន៍ទេ តែជារឿងដែលត្រូវថ្កោលទោសយ៉ាងមុឹងម៉ាត់បំផុត"។

# ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ហើយមិនឈប់!



ថតដោយ: សហការី ស៊ីអេសស៊ី

លោកបញ្ជាក់ថា "ពេលខ្លះមនុស្សវាច្រើនខ្ញុំជ្រុលបុកគូទឡានគេ ម្ចាស់ខ្លះមិនទាំងចុះមើលផង ហើយពេលខ្លះគេចុះមើល ខ្ញុំសូមទោសគេទៅ គេក៏មិនថាអីដែរ"។

ជុំវិញករណីគ្រោះថ្នាក់ចរាចរណ៍នេះ អ្នករត់ម៉ូតូឌុបម្នាក់ ដែលសុំមិនបញ្ចេញឈ្មោះបានលូកមាត់ថា សម្រាប់លោកឲ្យតែប៉ះគេ គឺលោករត់ហើយ បើរត់រួច តែបើរត់មិនរួចចាំសូមទោស ។

លោកបានបញ្ជាក់ថា "មិនរត់ម៉េច បើបុកគូទឡានគេតម្លៃរាប់ម៉ឺន បើគេចុះមកទារសងបានលុយឯណា ចឹងគេចបានគេ ហើយបើគិតមិនបានទេ សូមទោសអង្វរគេតាមហ្នឹងទៅ"។

ទម្លាប់ពេលជួបគ្រោះថ្នាក់ចរាចរណ៍ជិះរត់នេះ មិនមែនមានតែខាងរថយន្តនោះទេ គឺមានសព្វយានជំនិះ គ្រាន់តែវាមិនសូវល្បីខ្ចរខ្ចារដូចករណីរថយន្ត។

ជុំវិញករណីនេះដែរលោកជា មុនីរ័ត្ន អាយុ ៤៥ ឆ្នាំ ជាអ្នកបើកបររថយន្តមួយរូប បានឲ្យដឹងថា វាពិតជាពិបាក និយាយណាស់ រឿងករណីគ្រោះថ្នាក់ចរាចរណ៍ហើយមិនឈប់នេះ ។ លោកបានបន្តថា លោកធ្លាប់ជួបករណីគ្រោះ ថ្នាក់ចរាចរណ៍នេះដែរ ប៉ុន្តែសំណាងលោកមិនបានជួបហេតុការណ៍ ធ្ងន់ធ្ងរហួតកើតមានជាករណីហិង្សាកើតឡើង ដោយសារតែលោកច្រើនតែរងគ្រោះនឹងគេជិះម៉ូតូបុករថយន្តលោក។ ហើយករណដែលលោកប៉ះគេ គឺច្រើនតែប៉ះគ្នាជាមួយនឹងរថយន្ត និងរថយន្តតែជាការប៉ះបន្តិចបន្តួច គ្រាន់តែសូមទោស ហើយចេញថ្លៃខូចខាតតិចតួចក៏រួចគ្នា។

លោកបានបន្តថា ចំពោះករណីដែលអ្នកបង្កគ្រោះថ្នាក់ចរាចរណ៍ជិះបុករថយន្តលោកភាគច្រើនគឺរត់ហើយបើរត់មិនរួច គឺបានត្រឹមតែសូមទោសតែប៉ុណ្ណោះ តែលោកក៏មិនដែលរវល់ចាប់ទោស អូសដំណើរអ្វីនោះដែរ។

លោកបានបន្តថា ការបើកបរនៅលើទ្រូងផ្លូវ គឺដាច់ខាតមិនអាចជៀសរួចពីការប៉ះពារនោះទេប៉ុន្តែការយល់យោគអធ្យាស្រ័យដាច់ខាតត្រូវតែមាន និងត្រូវប្រកាន់យកប្រសិនជាមានការប៉ះពារ។

ទាក់ទិននឹងគ្រោះថ្នាក់ចរាចរណ៍ ហើយវិវត្តទៅជាអំពើហិង្សាវិញ ឧទាហរណ៍ជាក់ស្តែង ដូចជាករណីកើតមាននៅថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៨ ដែលបានបណ្តាលឲ្យបុរសម្នាក់ដែលគេដឹងថា លោកជាបណ្ឌិតមានមុខមាត់មួយរូបនៅក្នុងសង្គម ត្រូវបានប្រជាពលរដ្ឋជាច្រើននាក់បានចោមរោមវាយរហូតដល់បែកក្បាល បែកមុខមាត់ និងទ្រោមខ្លួន ហើយក៏ត្រូវបានបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យកាល់ម៉ែត និងបន្តទៅប្រទេសវៀតណាម ចំណែករថយន្តរបស់លោក ត្រូវបានពលរដ្ឋវាយកម្ទេចខូចខាតទាំងស្រុងមុនពេលសមត្ថកិច្ចចុះទៅធ្វើអន្តរាគមន៍ នៅកន្លែងកើតហេតុពលរដ្ឋបានបញ្ចេញយោបល់ថា នេះអាចបណ្តាលមកពី ករណីមិនគោរពច្បាប់ និងខ្វះការយោគយល់។

លោក បញ្ញារ័ន្តបានថ្លែងថា វាពិតជារន្ធត់ណាស់ នៅពេលដែលបានឃើញតាមរយៈវីដេអូដែលគេបានចែករំលែកតៗគ្នានៅលើបណ្តាញសង្គម។ លោកបានបញ្ជាក់ថា "មិនរន្ធត់ម៉េចបើឃើញសុទ្ធតែដុំថ្ម មកវាយមនុស្សទាំងស្រស់ៗ ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នោះ"។

លោក បានបន្តថា តាមរូបភាពវីដេអូដែលគេបានចែករំលែក អ្នកដែលបានឃើញហេតុការណ៍នោះ គឺមានច្រើនប៉ុន្តែភាគច្រើន គឺជាអ្នកឈរមើល ហើយអ្នកដែលចូលពាក់ព័ន្ធនឹងអំពើហិង្សា ក៏មានច្រើនដែរ ប៉ុន្តែមានតែ ប៉ុន្មានអ្នកទេ ដែលមានសភាពក្លៀវក្លាជាងគេ ។

លោកបានបញ្ជាក់ថា "មិនយល់ មិនដឹងយ៉ាងម៉េចបានជានាំគ្នាលើកដៃ លើកជើងទៅវាយទាត់ធាក់ មនុស្សដូចគ្នាកើត?"។

លោកបានបន្តថា បើគាត់ខុសគួរតែនាំខ្លួនគាត់ទៅឲ្យប៉ូលីសទៅចប់ហើយ ហេតុអ្វីក៏ចេះតែវាយគ្នាទៅកើត។

លោក ជឿ សុខនឿន ជាប្រជាពលរដ្ឋមួយរូបបានថ្លែងថា បញ្ហានេះ វាអាចដោយសារតែច្បាប់ចន្លោះប្រហោង។ លោកបានបន្តថា កន្លងមក វាអាចដោយសារតែពលរដ្ឋឃើញអ្នកមានលុយ អ្នកមានឡានទំនើបចេះតែរួចខ្លួន ពេលបុកគេបុកឯង ក៏កើតមានកំហឹង ប៉ុន្តែរឿងវាយគេបែបនេះ មិនត្រូវទាល់តែសោះ។

លោកបញ្ជាក់ថា "យើងដឹងថា នៅពេលនេះ ច្បាប់នៅមានចន្លោះប្រហោង ហើយការអនុវត្តច្បាប់ក៏វានៅធកល្វែង ប៉ុន្តែបើសិនជាយើងទាំងអស់គ្នាមិនអនុវត្តសង្គមយើងនៅតែធកល្វែង ដូច្នេះរហូតឬ?

ដោយឡែកមន្ត្រីសមត្ថកិច្ចប៉ូលីសមួយរូប បានមានប្រសាសន៍ពេលសម្រាកទទួលទានកាហ្វេ ដោយមិនបញ្ចេញអត្តសញ្ញាណថា វាពិតជាពិបាកបន្ទោសណាស់ រឿងគ្រោះថ្នាក់តិចតួចក្លាយជាកំហឹង។ លោកបានបន្តថា នៅក្នុងនាមជាសមត្ថកិច្ច លោកបានជួបករណីច្រើនហើយ មិនថាតែរឿងចរាចរណ៍ទេ រឿងវាយតប់ ហិង្សាខ្លះក៏ដូច្នេះដែរ។ លោកបានបន្តថា ពេលមានរឿង ភាគច្រើនមិននាំគ្នាយកច្បាប់មកដោះស្រាយទេ គឺអាងរៀងខ្លួន។

លោកបញ្ជាក់ថា "អ្នកមាន គេអាងលុយ អាងបក្សអាងពួក អាងខ្សែ ដល់អ្នកក្រីក្រ ពេលមានរឿង គឺអាងគ្នីអាងគ្នា ដល់ចឹងអត់មានអ្នកណាអាងច្បាប់ ទើបបានចេះតែកើតរឿងជាបន្តបន្ទាប់"។

លោកបានបន្តទៀតថា វាគ្រោះថ្នាក់ណាស់ សម្រាប់សង្គមទៅថ្ងៃអនាគត ប្រសិនបើម្នាក់ៗ នៅតែដោះស្រាយបញ្ហាដោយសារតែអារម្មណ៍បែបនេះ។ នរណាក៏ខឹង នរណាក៏ស្អប់ បើជួបហេតុការណ៍បែបនេះ ប៉ុន្តែហេតុអ្វីបានជាយើងនៅតែកសាងរូបភាពបែបនេះនៅក្នុងសង្គម ។

ដោយឡែក លោក ម៉េងឃន វិញបានលើកឡើងថា លោកពិតជាមិនដឹងដាក់កំហុសលើអ្នកណាឲ្យប្រាកដទេ ប៉ុន្តែគ្រប់ទំនាស់ទាំងអស់ សូមយកច្បាប់មកដោះស្រាយ ហើយការដោះស្រាយនោះ សូមកុំយកកំហល់ទៅដោះស្រាយ។ ដោះស្រាយដោយចិត្តត្រជាក់មានហេតុមានផល មានការអធ្យាស្រ័យឲ្យគ្នា យោគយល់គ្នា មិនមែនអាងនេះអាងនោះឡើយ ។

*ដោយអរិយបុត្រ*

## សមត្ថកិច្ចចាប់ខ្លួនមនុស្ស ៣ នាក់ ក្នុងករណីបង្កហិង្សានៅតាមទីសាធារណៈ

អគ្គស្នងការនគរបាលជាតិបានអះអាងថា សមត្ថកិច្ចបានចាត់វិធានការណ៍ផ្លូវច្បាប់ ដោយចាប់ខ្លួន អ្នកបង្កអំពើហិង្សានៅលើទ្រូងផ្លូវចំនួន ៣នាក់។

គេហទំព័ររបស់អគ្គស្នងការនគរបាលជាតិ បានអះអាងថា ពួកគេគឺសុទ្ធសឹងតែជាជនសង្ស័យ ដែលគេដឹងថា បានចូលរួមសកម្មភាពហិង្សា លើលោកបណ្ឌិតមួយរូបនៅក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ ។

ប្រភពដដែលបានបន្តថា ពួកគេត្រូវចាប់ខ្លួន ក្រោយពាក់ព័ន្ធនឹងការប្រើអំពើហិង្សាវាយអ្នកបើកបររថយន្តរហូតត្រូវបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ហើយបាត់បង់ទ្រព្យសម្បត្តិក៏ដូចជារថយន្ត។

នេះអាចជាករណីទីមួយ ដែលជនសង្ស័យបង្កអំពើហិង្សានៅទីសាធារណៈជាសមូហភាពត្រូវបានចាប់ខ្លួនក្រោយពេល ដែលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ខណៈដែល អំពើហិង្សាបែបនេះធ្លាប់បានកើតមាននៅក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ ជាពិសេសគឺករណីចោរកម្មផ្សេងៗ។

# បុណ្យប្រសិទ្ធីពរលើប្រេង នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា

លោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីអង្គ លោកបូជាចារ្យកាតូលិកទាំងអស់ដែលបំពេញមុខងារនៅកម្ពុជា បានប្រារព្ធអភិបូជាប្រសិទ្ធីពរលើប្រេងសម្រាប់ព្រះសហគមន៍ទាំងអស់ ឲ្យធ្វើជាសាក្សីនៃព្រះយេស៊ូដែលជាប្រពៃណីព្រះសហគមន៍កាតូលិក ដោយមានការចូលរួមពីសំណាក់គ្រីស្តបរិស័ទកាតូលិកមកពីភូមិភាគភ្នំពេញ បាត់ដំបងនិងកំពង់ចាមជាច្រើនរយនាក់។ ពិធីនេះបានប្រារព្ធនារសៀលថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ នៅព្រះវិហារសន្តសិលានិងសន្តប៉ូល ក្នុងមណ្ឌលសកម្មភាពភ្នំពេញថ្មី របស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។

លោកស៊ាន់ សារឿន ប្រធានការិយាល័យយុវជន ជំទង់ និងកុមារ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រកាសក្នុងពិធីអំពីអត្ថន័យនៃប្រេងទាំងបីប្រភេទដែលហែរយកមកប្រសិទ្ធីពរ និងទុកជានិមិត្តរូបនៃព្រះវិញ្ញាណដែលជាព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់ដែលបានជ្រួតជ្រាបនូវគំនិតព្រមទាំងប្រទាននូវកម្លាំង និងអំណរសប្បាយដល់អស់អ្នកដែលជឿ។



នៅពេលតំណាងគ្រីស្តបរិស័ទ និងជាតំណាងគណៈកម្មាធិការសំខាន់ទាំងបីមានគណៈកម្មការពិធីបុណ្យ គណៈកម្មការសង្គហៈ និងគណៈកម្មការអប់រំជំនឿ នៃព្រះសហគមន៍កាតូលិកបានហែថូប្រេងទាំងបីប្រភេទចូលមកក្នុងអង្គពិធីជូនលោកអភិបាលដែលរង់ចាំទទួល។ ពេលទទួលប្រេងនោះហើយ លោកអភិបាល អធិដ្ឋានទូលអង្វរព្រះជាម្ចាស់ទៅតាមប្រភេទនៃប្រេងដែលត្រូវប្រើស្របតាមប្រពៃណីនៃព្រះសហគមន៍កាតូលិកផងដែរ។

តំណាងគ្រីស្តបរិស័ទបានយកប្រេងគ្រីស្មាជូនលោកអភិបាលអូលីវីយេ លោកទទួលហើយបានចាក់ប្រេងក្រអូបចូលក្នុងថូ លាយបញ្ចូលគ្នា និងបានផ្លុំលើប្រេងទាំងនេះដើម្បីបញ្ជាក់ថាព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និងអធិដ្ឋានដោយនឹកដល់អត្ថសញ្ញានានានឹកដល់ឫទ្ធិបារមីនៃប្រេងពិសិដ្ឋនៅក្នុងសម្ពន្ធមេត្រីចាស់ នឹកដល់ព្រះយេស៊ូដែលបំពេញបេសកកម្មសង្គ្រោះមនុស្សលោក ហើយទូលអង្វរព្រះជាម្ចាស់ដល់ព្រះសហគមន៍ដើម្បីបន្តបេសកកម្មតាមរយៈប្រេងពិសិដ្ឋនេះ ដើម្បីឲ្យមនុស្សលោកបានទទួលព្រះពរនិងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ដែលបានកើតជាថ្មីដោយអត្ថសញ្ញាជ្រមុជទឹក និងអត្ថសញ្ញានានាដែលបានប្រើដោយប្រេងនេះ។

លោកអភិបាល រួមជាមួយអស់លោកបូជាចារ្យទាំងអស់ទ្រាបដៃលើប្រេង ទូលអង្វរព្រះជាម្ចាស់និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យប្រេងដែលលាយជាមួយគ្រឿងក្រអូបទាំងនេះបានទៅជាអត្ថសញ្ញាបង្ហាញពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ និងសូមឲ្យប្រេងទាំងនេះពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីឲ្យអស់អ្នកដែលទទួលប្រេងនេះបានសេចក្តីសុខសាន្ត។

ប្រេងដែលបានប្រសិទ្ធីពរនោះមានបីយ៉ាងបន្តបន្ទាប់គ្នាគឺ ដំបូងជា ប្រេងសម្រាប់លាបដើម្បីផ្តល់កម្លាំងឲ្យអ្នកជំងឺ ចាស់ជរា ជនពិការ និងអស់អ្នកដែលរងទុក្ខលំបាក។ បន្ទាប់ជា ប្រេងសម្រាប់អ្នករៀបចំខ្លួនទទួលអត្ថសញ្ញាជ្រមុជទឹក និងអស់អ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូ។ចុងក្រោយជា ប្រេងគ្រីស្មាដែលប្រើសម្រាប់អត្ថសញ្ញាលាប ថ្វាសសម្រាប់អស់អ្នកដែលស្ម័គ្រចិត្តថ្វាយខ្លួនជាអ្នកបម្រើព្រះជាម្ចាស់ សម្រាប់អត្ថសញ្ញាតែងតាំងជាបូជាចារ្យជាអភិបាល និងសម្រាប់ទីសក្ការៈនានានៃព្រះសហគមន៍ ទាំងអស់ដើម្បីធ្វើជាសាក្សីនៃព្រះយេស៊ូ។

ពិធីនេះតែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំក្នុងរដូវអប់រំពិសេសមុនចូលក្នុងសប្តាហ៍ពិសិដ្ឋ ដើម្បីយកទៅប្រើប្រាស់ក្នុងពិធីផ្សេងៗរបស់ព្រះសហគមន៍កាតូលិកពេញមួយឆ្នាំ ៕

*ដោយ ដាលីស*

# ព្រះសហគមន៍កាតូលិក ចំប៉ា បង្ហាញឲ្យគ្រីស្តបរិស័ទស្គាល់ពីគំរូនៃសន្តយ៉ូសែប

រូបសំណាកសន្តយ៉ូសែប ត្រូវបានរៀបចំយ៉ាងសមរម្យ នៅលើគ្រែស្នែង ហែក្នុងភូមិយ៉ាងឱឡារិក តម្រង់មក ព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ (ចំប៉ា) នៃមណ្ឌលសកម្មភាពទន្លេមេគង្គ ក្នុងឱកាសបុណ្យគោរពសន្តយ៉ូសែបជាស្វាមី ស្របតាមប្រក្រតិទិនរបស់ព្រះសហគន៍កាតូលិក។

ពិធីបុណ្យនេះដឹកនាំដោយលោកវីរៈជ័យ ស្រ៊ីប្រាម៉ុង បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពមេគង្គ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដោយមានគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ នារសៀលថ្ងៃទី១៩ មីនា ២០១៨ នៅភូមិជ្រោយអំពិល ស្រុកគៀនស្វាយ ខេត្តកណ្តាល។

ពិធីដង្ហែរូបសំណាកសន្តយ៉ូសែប គឺប្រារព្ធយ៉ាងឱឡារិក និងឈប់អធិដ្ឋាននៅតាមដំណាក់កាលនីមួយៗនៅតាមផ្ទះរបស់អ្នកភូមិ រហូតមកដល់ព្រះវិហារដើម្បីប្រារព្ធពិធីអភិបូជា។

សន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាងម៉ារី និងជាបិតាចិញ្ចឹមរបស់ព្រះយេស៊ូ។ តាមគម្ពីរដែលរាបរៀងដោយលោកម៉ាថាយ បានបញ្ជាក់ថាសន្តយ៉ូសែប ជាប់ខ្សែស្រឡាយជាមួយព្រះបាទដាវីឌ ដែលនាំឲ្យព្រះយេស៊ូ ជាប់ខ្សែស្រឡាយព្រះបាទដាវីឌដែរ។ លោកសុខចិត្តទទួលព្រះនាងម៉ារី ធ្វើជាភរិយា ទាំងព្រះនាងមានផ្ទៃពោះដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកខិតខំថែរក្សា និងថែទាំក្រុមគ្រួសារ ដោយយកចិត្តទុកដាក់បំផុត។



តាមប្រសាសន៍របស់លោកបូជាចារ្យវីរៈជ័យស្រ៊ីប្រាម៉ុង បានឲ្យដឹងថា ព្រះវិហារនៅទីនេះមានសន្ត ហ្វ្រង់ស្វ័រសាវីយេ ជាឧបការីក៏ពិតមែន តែដោយឡែកក្នុងឆ្នាំនេះជាឆ្នាំនៃគ្រួសារហើយសន្តយ៉ូសែបជាគំរូនៃមេគ្រួសារដ៏ល្អ ទើបព្រះសហគមន៍រួមជាមួយគណៈកម្មាធិការទាំងអស់ឯកភាពគ្នាប្រារព្ធពិធីនេះឡើង ដើម្បីរំឭក និងជួយដាស់តឿនគ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់ទទួលខុសត្រូវ ស្រឡាញ់ក្រុមគ្រួសារ ខិតខំធ្វើការរកស៊ី និងរក្សាកូនឲ្យបានល្អតាមរបៀបរបស់សន្តយ៉ូសែប។

លោកបូជាចារ្យបានបន្ថែមថា បច្ចុប្បន្នគ្រីស្តបរិស័ទនៅចំប៉ាមិនសូវមានអ្នកយកឈ្មោះសន្តយ៉ូសែបមកធ្វើជាឧបជ្ឈាយ៍របស់ខ្លួននោះទេ។ កត្តាទាំងនេះទើបលោកវីរៈជ័យចង់បង្ហាញនិងរំឭកអំពីប្រវត្តិរបស់សន្តយ៉ូសែបដល់អស់គ្រីស្តបរិស័ទឲ្យចាប់អារម្មណ៍។ លោកបញ្ជាក់ទៀតថា ព្រះសហគមន៍នឹងប្រារព្ធពិធីនេះជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំផងដែរ ៕

*ដោយ ដាលីស*

# បេក្ខជន២៦រូបទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះវិហារព្រះកុមារយេស៊ូ



បងប្អូនចំនួន ២៦រូប ទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះវិហារព្រះកុមារយេស៊ូ ក្នុងសង្កាត់បឹងទំពុនរាជធានីភ្នំពេញ យ៉ាងឱឡារិកនារាត្រីបុណ្យចម្លង ដែលព្រះយេស៊ូជាអម្ចាស់មានព្រះជន្មរស់ឡើងវិញ ត្រូវនឹងថ្ងៃទី៣១ មីនា ២០១៨ ដែលមានគ្រីស្តបរិស័ទប្រមាណជាង៣០០នាក់ ចូលរួមក្រោមការដឹកនាំដោយលោក ដាមីញ៉ាំង ហ្វានីរ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ និងជាប្រធានមណ្ឌលសកម្មភាពភ្នំពេញខាងត្បូងនៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

នៅក្នុងធម្មទេសនា នាពិធីបុណ្យយ៉ាងឱឡារិកនេះ លោកបូជាចារ្យ ដាមីញ៉ាំ បានមានប្រសាសន៍ថា ព្រះយេស៊ូបានឈ្នះលើសេចក្តីស្លាប់ គឺមានប្រយោជន៍សម្រាប់យើងជាពិសេសបងប្អូនដែលរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក គឺយើងរួមស្លាប់ជាមួយព្រះយេស៊ូដើម្បីទទួលសិរីរុងរឿងជាមួយព្រះអង្គដោយអគ្គសញ្ញានេះ។ លោកបន្ថែមថា "បងប្អូននឹងអាចភ្លេចព្រះយេស៊ូ តែព្រះយេស៊ូមិនដែលភ្លេចយើងទេ"។ លោកដាមីញ៉ាំងបន្តទៀតថា ពេលយើងប្រកាសអំពីព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង យើងក៏បានដោះកំណាត់សំពត់ ដែលបាំងឈើឆ្កាង ព្រោះឈើឆ្កាងជាសញ្ញាសម្គាល់អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់ ហើយនេះក៏ជាតួនាទីរបស់យើងដែលជាគ្រីស្តបរិស័ទក៏ត្រូវទទួលឈើឆ្កាង ដោយធ្វើជាអំបិល និងពន្លឺសម្រាប់បំភ្លឺពិភពលោកដែរ។

ក្រោយធម្មទេសនា បេក្ខជនទាំងអស់ត្រូវប្រកាសជំនឿរបស់ខ្លួន តាមសំណួររបស់លោកបូជាចារ្យ ចំពោះគ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាជ្រមុជទឹកយូរហើយក៏ត្រូវប្រកាសជំនឿតាមសំណួររបស់លោកបូជាចារ្យដែរ។

បន្ទាប់មកបេក្ខជនទាំង២៦រូបទទួលអគ្គសញ្ញាជ្រមុជទឹក ដោយចុះទៅក្នុងអាងតាមបែបប្រពៃណីព្រះសហគមន៍កាតូលិកបុរាណដែលជាសញ្ញាបង្ហាញថាអ្នកទាំងនោះបានរួមស្លាប់ រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត។ ពេលនោះ លោកបូជាចារ្យបានធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យបេក្ខជនក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងអាង និងលាបប្រេងគ្រីស្មាដែលបញ្ជាក់តាមជំនឿគ្រីស្តបរិស័ទថា ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយប្រេងនោះ។ ក្រោយពីលាបប្រេងរួច គ្រីស្តបរិស័ទដែលកំពុងតែទទួលអគ្គសញ្ញានេះក៏បានទទួលកន្សែងស (អាវពណ៌ស) ដែលបង្ហាញថាពួកគេបានមានជីវិតថ្មីរួមជាមួយព្រះយេស៊ូគ្រីស្ត និងទទួលទៀនដែលកំពុងឆេះដែលជាសញ្ញានៃវត្តមានព្រះពន្លឺរបស់ព្រះគ្រីស្តដែលមានព្រះជន្មថ្មីដ៏រុងរឿងគង់នៅជាមួយពួកគេ។

បេក្ខជន ថុង ធិន ដែលទើបតែទទួលអគ្គសញ្ញាជ្រមុជទឹកថ្មីៗ បាននិយាយថា ថ្ងៃនេះជាអំណរសប្បាយ និងរំភើបដែលបានធ្វើជាគ្រីស្តបរិស័ទដោយមានបងប្អូនមកចូលរួមអបអរសាទរ។ ថុង ធិន មកពីគ្រួសារដែលមានជំនឿលើសាសនាព្រះពុទ្ធមាំមួន។ ធិន បញ្ជាក់ថា ជាគ្រីស្តបរិស័ទគឺសប្បាយ។ សប្បាយដោយចេះរួមគ្នា ចេះស្រឡាញ់គ្នា និងចេះជួយអ្នកដទៃ។ គ្រីស្តបរិស័ទថ្មីរូបនេះបានប្តេជ្ញាចិត្តថា នៅថ្ងៃក្រោយរូបគេនឹងចូលរួមជាមួយក្រុមកាយឫទ្ធិរបស់ព្រះសហគមន៍ និងក្រុមចម្រៀងដើម្បីបញ្ចេញសកម្មភាពខ្លះៗក្នុងព្រះសហគមន៍។

*ដោយ ដាលីស*

# កម្មវិធីបញ្ចុះបឋមសិលាសាលាសន្តីហាណ្ណា ( Anne school )

កាលពីថ្ងៃទី៣ មេសាកន្លងទៅនេះ ក្រុមគ្រួសារ បងស្រី ប្រៀនប្រដៅនៃព្រះគ្រីស្ត ( sisters of Christian Doctrine ) នៅភូមិបន្ទាយដីលើ សង្កាត់បន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានរៀបចំកម្មវិធីបញ្ចុះបឋមសិលាសាលាសន្តី ហាណ្ណា ក្រោមអធិបតីភាពលោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង រួមនឹងលោកមេឃុំ មេភូមិ និងបងប្អូនពលរដ្ឋយ៉ាងច្រើនកុះករ។ បងស្រី ក្វាកយុនហេ ជាដូនជីកាតូលិកនៃក្រុមគ្រួសារបងស្រីប្រៀនប្រដៅនៃព្រះគ្រីស្ត បានមានប្រសាសន៍ថា អាគារនេះសាងសង់ឡើង ដើម្បីជាកន្លែងអប់រំកុមារ និងយុវជន ដោយបង្រៀនភាសាអង់គ្លេស សុជីវធម៌ និងអនាម័យ។ អគារថ្មីនេះនឹងជួយសម្រួលដល់កិច្ចការងាររបស់បងស្រីក្នុងកិច្ចការអប់រំ ដែលមានបន្ទប់រៀនចំនួន៣ បណ្ណាល័យមួយ ការិយាល័យសិក្សា និងបន្ទប់ស្នាក់នៅសម្រាប់យុវនារី ដែលមកពីបណ្តាស្រុកឆ្ងាយៗពីទីរួមខេត្តពោធិ៍សាត់។ ស្ថិតក្នុងបរិយាកាសដ៏សែនសប្បាយ លោកនូ នឿង ចៅសង្កាត់បន្ទាយដី ថ្លែងអំណរគុណចំពោះសកម្មភាពរបស់ក្រុមបងស្រីក្នុងការអប់រំកុមារនិងយុវជននៅក្នុងខេត្តពោធិ៍សាត់នេះ។ លោកថា ការអប់រំពិតជាមានសារៈសំខាន់ណាស់ ក្នុងការកសាងធនធានមនុស្ស ដើម្បីឲ្យប្រទេសជាតិយើងរីកចម្រើន។ លោកបានបន្តថា បច្ចុប្បន្នប្រទេសកម្ពុជា ពោរពេញដោយសន្តិភាពយ៉ាងពិតប្រាកដ មានការអភិវឌ្ឍជាច្រើន និងកំពុងរីកចម្រើន។ ជាមួយគ្នានេះដែរ លោក អេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានប្រសាសន៍លើកទឹកចិត្តក្រុមបងស្រីទាំងអស់ដែលបានបង្ហាញរបៀបរស់នៅបែបសុភាពរាបសារ និងជាគំរូសម្រាប់យុវជននៅទីនេះ។ លោកក៏បានផ្តាំផ្ញើដល់យុវជន ឲ្យខិតខំរៀនសូត្រ ដើម្បីមានចំណេះដឹងល្អសម្រាប់អនាគត។ លោកក៏បានរំឭកដល់អ្នកចូលរួមទាំងអស់ ឲ្យមានចិត្តដូចជាកូនក្មេង ដែលព្រះយេស៊ូនិយាយក្នុងព្រះគម្ពីរ ព្រោះកូនក្មេងមានចិត្តល្អ ទូលំទូលាយសុភាពរាបសារ។ លោកក៏សូមឲ្យបងប្អូនចេះបម្រើសង្គមដោយចិត្តសុភាព និងសេចក្តីស្រឡាញ់។ លោកអភិបាលបានជំរុញឲ្យយុវជន និងគ្រីស្តបរិស័ទត្រូវអរព្រះគុណព្រះជាម្ចាស់ ហើយត្រូវទទួលស្គាល់ព្រះអំណោយទាន ដែលយើងមាន និងឲ្យយុវជន ព្រមទាំងណៈកម្មាការ ត្រូវជួយថែរក្សាបងស្រីដែលនៅក្នុងផ្ទះនេះហើយ ចូលរួមក្នុងសកម្មភាពអប់រំដែលបងស្រីមានក្នុងផ្ទះ និងក្នុងសាលានេះ។ ក្រោយពីពិធីសំណេះសំណាល និងអធិដ្ឋាន លោកអភិបាលរួមជាមួយលោកចៅសង្កាត់ បងស្រីប្រធាន បានប្រារព្ធពិធីអធិដ្ឋាន បញ្ចុះគ្រឹះសិលា រួមនិងឈើឆ្កាងក្នុងដីនៃកន្លែងត្រូវសាងសង់អាគារនោះ តាមរបៀប និងជំនឿកាតូលិក។ ក្រុមដូនជីកាតូលិក ក្រុមគ្រួសារបងស្រី ប្រៀនប្រដៅនៃព្រះគ្រីស្ត ( sisters of Christian Doctrine ) បានមកដល់ពោធិ៍សាត់ប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយបានបំពេញបេសកកម្មក្នុងការជួយប្រជាជនតាមសហគមន៍ជុំវិញក្រុងពោធិ៍សាត់ បំពេញការងារផ្នែកអប់រំចំណេះដឹងទូទៅ ភាសាអង់គ្លេស ភាសាកូរ៉េជាដើម។



# លោកបូជាចារ្យទាំងអស់ ប្រកាសពាក្យសច្ចារបស់ខ្លួន សារឡើងវិញ

លោកបូជាចារ្យទាំងអស់ ដែលមានវត្តមាននៅលើទឹកដីប្រទេសកម្ពុជាបានប្រកាសពាក្យសច្ចារបស់ខ្លួនសារជាថ្មីយ៉ាងឱឡារិកនៅចំពោះមុខលោកអភិបាល និងចំពោះមុខព្រះសហគមន៍ក្នុងពិធីប្រសិទ្ធីពរលើប្រេង នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ក្នុងមណ្ឌលសកម្មភាពភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ នាល្ងាចថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ កន្លងទៅនេះដោយមានគ្រីស្តបរិស័ទជាច្រើនរយនាក់ចូលរួម។

ក្នុងធម្មទេសនាលោកអភិបាលអូលីវីយេជាអធិបតី បានមានប្រសាសន៍ទៅកាន់អស់លោកបូជាចារ្យ ទាំងអស់ឲ្យសម្លឹងមើលព្រះហស្តរបស់ព្រះយេស៊ូ ដោយមានប្រសាសន៍ថា យើងជាបូជាចារ្យ យើងបានទទួលឋានៈពិសេសតាមរយៈប្រេងអភិសេកដោយលោកអភិបាលលាតដៃឲ្យយើងធ្វើជាបូជាចារ្យដែលព្រះជាម្ចាស់បានជ្រើសរើស និងតែងតាំងយើងទៅជាអ្នកបម្រើរបស់ព្រះជាម្ចាស់អស់ពីដួងចិត្ត។

លោកបន្តថា នៅពេលយើងទទួលអគ្គសញ្ញា គឺពោរពេញដោយថាមពលនៃសេចក្តីស្រឡាញ់ប្រៀបដូចជាជីវិតរបស់លោកសិលាដែរ ជួនកាលយើងធ្លាក់ចុះដូចលោកសិលាលិចទៅក្នុងទឹកតែយើងដឹងថាព្រះយេស៊ូស្រឡាញ់យើង ចាប់ដៃយើងនៅជាមួយយើង និងលើកលែងទោសឲ្យយើងគ្រប់ពេល។

លោកអភិបាលបានក្រើនរំឭកដល់អស់លោកបូជាចារ្យអំពីដៃដោយមានប្រសាសន៍នឹកដល់ពេលវេលាតែងតាំងជាបូជាចារ្យ នឹកដល់ដៃលោកអភិបាល នឹកដល់ដៃដែលទ្រាបលើនំព្រះកាយ ដៃដែលទទួលស្វាគមន៍បងប្អូនដែលអស់សង្ឃឹមឲ្យមានសង្ឃឹមឡើងវិញនៅក្នុងជីវិត ដៃដែលប្រណម្យអធិដ្ឋាន ដើម្បីឲ្យជិតស្និទ្ធជាមួយព្រះយេស៊ូ។

លោកអូលីវីយេអញ្ជើញ លោកបូជាចារ្យឲ្យសម្លឹងមើលព្រះហស្តរបស់ព្រះយេស៊ូផ្ទាល់ជាពិសេសនៅក្នុងឆ្នាំគ្រួសារនេះ សូមលោកបូជាចារ្យមានទឹកចិត្តដូចម្តាយផងមានចិត្តដូចឪពុកផង ដើម្បីបម្រើបងប្អូនយើង ដើម្បីណែនាំឲ្យបងប្អូនឲ្យបានវិសុទ្ធ ដើម្បីស្រឡាញ់ដូចព្រះជាម្ចាស់ ដើម្បីលើកលែងទោសដូចព្រះជាម្ចាស់ ដើម្បីបម្រើដូចព្រះជាម្ចាស់។ លោកបានសង្កត់ធ្ងន់ថា "យើងជាបូជាចារ្យ យើងជាព្រះមហាក្សត្រ យើងជាព្យាការី សូមឲ្យយើងប្រមូលសេចក្តីស្រឡាញ់ ដោយដៃរបស់យើង ដើម្បីឲ្យបងប្អូនរបស់យើងមានជីវិតដ៏បរិបូណ៌"។

បន្ទាប់ពីធម្មទេសនា លោកអភិបាលអូលីវីយេបានអញ្ជើញលោកបូជាចារ្យទាំងអស់ ដើម្បីប្រកាសពាក្យសច្ចារបស់ខ្លួនសារជាថ្មីឡើងវិញ ដោយមានប្រសាសន៍អំពីការនឹករឭកដល់ព្រះយេស៊ូបានត្រាស់ហៅពួកសាវ័ក និងត្រាស់ហៅលោកបូជាចារ្យម្នាក់ៗ ព្រមទាំងលើកជាសំណួរទៅកាន់លោកបូជាចារ្យទាំងអស់ថា តើបងប្អូនចង់ប្រកាសនូវពាក្យសច្ចាប្រណិធានរបស់ខ្លួនសារជាថ្មី នៅចំពោះមុខលោកអភិបាល និងមុខប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឬទេ?

ស្របពេលនេះដែរលោកបូជាចារ្យទាំងអស់បានប្តេជ្ញាបញ្ជាក់នូវពាក្យសច្ចារបស់ខ្លួនសារជាថ្មី នៅចំពោះមុខលោកអភិបាលរបស់ខ្លួន និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដោយចង់រួមស្លាប់រួមរស់ជាមួយព្រះយេស៊ូឲ្យអស់ពីចិត្តដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រកាសយ៉ាងស្មោះត្រង់តាមពាក្យសច្ចាព្រមទាំងបំពេញបេសកកម្មរបស់ខ្លួនក្នុងព្រះសហគមន៍តាមព្រះគ្រីស្តជាគង្វាលដ៏ប្រពៃ ដោយបម្រើគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ តាមរយៈព្រះបន្ទូលព្រះអង្គ ថ្វាយអភិបូជា និងពិធីបុណ្យផ្សេងៗ។

បន្ទាប់មកលោកអភិបាលបានស្នើឲ្យគ្រីស្តបរិស័ទទាំងអស់ ជួយអង្វរព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់អស់លោកបូជាចារ្យ។ លោកបន្ថែមទៀតថា សូមអង្វរព្រះជាម្ចាស់ចាក់បង្ហូរព្រះអំណោយទានលើលោកបូជាចារ្យយ៉ាងបរិបូរណ៌ ដើម្បីជួយអស់លោកឲ្យចេះបម្រើព្រះជាម្ចាស់ដោយស្មោះត្រង់ និងណែនាំបងប្អូនទៅដល់ប្រភពនៃការសង្គ្រោះ។ លោកបន្តថា សូមបងប្អូនអង្វរព្រះជាម្ចាស់សម្រាប់ខ្ញុំ និងអស់លោកអភិបាល។

លោកអភិបាលមានប្រសាសន៍ទៀតថា ទោះបីយើងខ្ញុំមិនសមទទួលបន្ទុកនេះក៏ដោយ តែសូមព្រះជាម្ចាស់ជួយឲ្យយើងខ្ញុំចេះបំពេញមុខងារដោយស្ម័គ្រចិត្ត និងមានភក្តីភាពក្នុងនាមព្រះគ្រីស្តជាមហាបូជាចារ្យ ជាគង្វាលដ៏សប្បុរស ជាបរមគ្រូ និងជាអ្នកបម្រើមនុស្សទាំងឡាយ។

ជាចុងក្រោយលោកអភិបាលបានទូលអង្វរព្រះជាម្ចាស់ដើម្បីប្រមូល និងថែរក្សាមនុស្សទាំងអស់ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។

ពិធីរំឭកពាក្យសច្ចានេះតែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីលើកទឹកចិត្តអស់លោកបូជាចារ្យក្នុងការធ្វើដំណើររួមជាមួយព្រះយេស៊ូ តាមរយៈការបម្រើព្រះសហគមន៍ បម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដោយសេចក្តីស្រឡាញ់។

បន្ទាប់ពីអភិបូជាលោកបូជាចារ្យទាំងអស់បានទទួលផ្កាដែលតំណាងឲ្យសេចក្តីស្រឡាញ់ និងការគោរពរបស់ព្រះសហគមន៍៕

*ដោយ ដាលីស*



# អង្គការករុណាបាត់ដំបង បានរៀបចំទិវាផ្សព្វផ្សាយការយល់ដឹងអំពីជំងឺអូទីសឹមពិភពលោក




កាលពីព្រឹកថ្ងៃច័ន្ទនេះអង្គការករុណាបាត់ដំបង បានរៀបចំទិវាផ្សព្វផ្សាយការយល់ដឹងអំពីជំងឺអូទីសឹមពិភពលាក ក្រោមអធិបតីភាពរបស់ លោកអេនរីគេ ហ្វីការេដូ ជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការនេះ រួមជាមួយ លោកសា រឿន ជាប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាខេត្តបាត់ដំបង ព្រមទាំងមានកុមារពិការច្រើនប្រភេទ រួមនឹងអាណាព្យាបាលមួយចំនួនចូលរួមយ៉ាងច្រើនកុះករ។ ពិធីនេះប្រារព្ធធ្វើឡើងនៅក្នុងបរិវេណព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខនៅបាត់ដំបងក្រុង នាព្រឹកថ្ងៃទី២ មេសា ឆ្នាំ២០១៨។

លោកអេនរីគេ ហ្វីការេដូជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការករុណាបាត់ដំបង និងជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងមានប្រសាសន៍ថា ការរៀបចំកម្មវិធីនេះឡើងគឺដើម្បីលើកទឹកចិត្តឪពុកម្តាយដែលមានកូនៗមានជំងឺអូទីសឹម ជាពិការភាពថ្មីនៅកម្ពុជា។ លើកទឹកចិត្តមាតាបិតា ឲ្យគេយល់ពីពិការភាព ដែលកូនៗត្រូវការអប់រំពិសេស។

លោកអភិបាលបានឲ្យថា កម្មវិធីនេះក៏ជួយផ្សព្វផ្សាយឲ្យក្រុមឪពុកម្តាយ ដឹងពីបញ្ហានេះ។ ជារឿងថ្មី នៅកម្ពុជា និងនៅក្នុងពិភពលោកដែរ។ ករុណាបាត់ដំបងបានខិតខំរកវិធី និងបានរៀនពីអង្គការផ្សេងៗ ដើម្បីជួយបង្រៀនកុមារ នៅក្នុងអង្គការ តាមផ្ទះ និងក្នុងសហគមន៍ក្នុងសាលារៀនដែរ ដើម្បីឲ្យគេយល់អំពីពិការភាពថ្មីនេះ។ លោកថា ក្នុងពេលរួមជាមួយឪពុកម្តាយ អង្គការរៀនពីឪពុកម្តាយអំពីបញ្ហាដែលមាន អំពីរបៀបទំនាក់របស់កូន របៀបការចាប់អារម្មណ៍របស់កូន។

លោកអភិបាលមានបន្ថែមថា ចំពោះកុមារទាំងនោះ ក្នុងនាមជាព្រះសហគមន៍គឺជាកិច្ចការមួយពិសេស ដែលត្រូវអប់រំពួកគាត់ទៅតាមសមត្ថភាពដែលមាន។ ព្រះសហគមន៍មានតួនាទីអប់រំកូនៗដែលមិនអាចចូលទៅក្នុងសង្គមបាន គ្មានអ្នកណាលើកទឹកចិត្ត ដោយសារយើងមានជំនឿថាយើងជាបុត្រធិតារបស់ព្រះជាម្ចាស់។ យើងត្រូវគិតដល់កុមារដែលមានពិការភាព។

លោកបានសង្កត់ធ្ងន់ថា យើងត្រូវដូរទស្សនៈ ថាកូននេះល្ងង់ មិនឆ្លាត រៀនមិនពូកែរ ពិបាកបង្រៀន។ ត្រូវដូរទស្សនៈ តាមកូនដែលមានរបៀបផ្សេងពីអ្នកដទៃ។ យើងត្រូវបង្រៀន និងណែនាំកូន យើងត្រូវរៀនរបៀបថ្មីដែរ បើកចិត្តឲ្យទូលាយ។ លោកថាពេលយើងប្តូរទស្សនៈ យើងនឹងយល់ពីកូនក្មេងជាច្រើន ទាំងនេះហើយនាំឲ្យយើងយល់ថា កុមារទាំងនោះជាព្រះអំណោយទាន។ នាំឲ្យយើងល្អជាង ជ្រៅជាង។ កុមារទាំងអស់ត្រូវការអប់រំផ្សេងៗគ្នា។

ថ្លែងប្រាប់នៅក្នុងអង្គប្រជុំនៃទិវានេះ លោកភួម សុផាត ប្រធានគម្រោងកម្មវិធីស្តារសមត្ថភាពជនពិការសតិបញ្ញានៃអង្គការករុណាបាត់ដំបង បានមានប្រសាសន៍ថា អូទីសឹម គឺជាពិការភាពនៃការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធប្រសាទ ដែលប៉ះពាល់ចម្បងលើផ្នែកសង្គម និងការទំនាក់ទំនងដែលស្តែងចេញនូវអាកប្បកិរិយាដដែលៗ ឬមានចំណាប់អារម្មណ៍ជាក់លាក់។ រោគសញ្ញានៃជំងឺនេះ លោកសុផាតឲ្យដឹងថា គេអាចកត់សម្គាល់ដឹងថាកុមារម្នាក់មានជំងឺអូទីសឹមនេះបានដោយកត្តាមួយចំនួនដូចជា៖ ពីអាយុ៦ខែ ឬលើស កុមារមិនចេះបង្ហាញភាពកក់ក្តៅដូចជា ញញឹម ឬសើចតប។ពីអាយុ១០ខែកុមារមិនប្រតិកម្មតបនៅពេលហៅ។ ហើយពីអាយុ១២ខែ កុមារមិនចេះនិយាយអ៊ឺអើ ឬកកេរកករ។ ហើយនៅអាយុ២៤ខែកុមារមិនចេះនិយាយជាឃ្លា ឬជាពាក្យ។ ពេលខ្លះកុមារក៏បាត់បង់នូវភាសានិយាយរបស់គាត់ក្នុងអាយុណាមួយ។ លោកប្រធានគម្រោងរូបនេះបានបញ្ជាក់ថា ប្រសិនបើឪពុកម្តាយបានឃើញកូនមានអាការៈមិនស្រួលបែបនេះ គួរទៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវជនដែលមានទីតាំងនៅមន្ទីរពេទ្យបង្អែកក្រុងតាខ្មៅក្នុងខេត្តកណ្តាលដើម្បីទទួលបានការប្រឹក្សា និងព្យាបាល។

ជំងឺអូទីសឹមនេះ ត្រូវបានគេទទួលស្គាល់ក្នុងផ្នែកពិការភាពតាំងពីឆ្នាំ២០០៨។ ទិវាផ្សព្វផ្សាយការយល់ដឹងអំពីអូទីសឹមត្រូវបានគេធ្វើឡើងជារៀងរាល់ថ្ងៃទី២ មេសា។ តាមរយៈការសិក្សារបស់អ្នកស្រាវជ្រាវលើចំនួនកុមារចំនួន១០ម៉ឺននាក់ត្រូវបានគេជ្រើសរើសនៅទូទាំងពិភពលោកក្នុងឆ្នាំ២០១៧ បានបង្ហាញថា ក្នុងនៅប្រទេសជប៉ុនមានកុមារ ដែលមានជំងឺអូទីសឹមនេះខ្ពស់ជាងគេ ដែលមានចំនួន១៦១នាក់ក្នុងចំណោមកុមារ ដែលបានជ្រើសរើសបន្ទាប់មក គឺចក្រភពអង់គ្លេស និងប្រទេសផ្សេងៗទៀតក្នុងតំបន់អឺរ៉ុប រួមនឹងសហរដ្ឋអាមេរិកផង។

នៅកម្ពុជា ស្ថានប័នតិចទួចប៉ុណ្ណោះដែលកំពុងធ្វើការ ជួយកុមារអូទីសឹម។

លោកសា រឿនជាប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាខេត្តបាត់ដំបងមានប្រសាសន៍ថា បច្ចុប្បន្នកម្ពុជាមិនទាន់មានមជ្ឍមណ្ឌលគាំទ្រណាមួយនៅក្នុងខេត្តដែលធ្វើការជាមួយអូទីសឹមនេះនៅឡើយទេ។

អង្គការករុណាបាត់ដំបងជាស្ថាប័នមួយរបស់ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងដែលធ្វើការងារខាងមនុស្សធម៌លើផ្នែកពិការភាព អូទីសឹម ខ្សោយសតិបញ្ញា ស្វិតដៃជើង ផ្នែកសិក្សាអប់រំ សហគ្រិនសង្គម និងផ្នែកអភិវឌ្ឍជនបទជាដើម។

# ពិធីបើកសម្ពោធជាផ្លូវការសាលមហោស្រពសិល្បៈនៅភូមិចំការទៀង



សាលមហោស្រពសិល្បៈ ដែលមានទំហំ២៣ម៉ែត្រ គុណនឹង១៨ម៉ែត្រ ដែលយកគំរូតាមរចនាបថ ភូមិវប្បធម៌បាន បើកសម្ពោធជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការនៃក្រសួងប្បធម៌ និងវិចិតសិល្បៈ លោកអូលីវីយេ ជ្មឹតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកស្រីប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងមន្ត្រីរាជការ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងសិស្សានុសិស្សចូលរួមជាច្រើនកុះករ នៅភូមិចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី៦ មេសា ២០១៨នេះ។

មុននឹងចាប់ផ្ដើមកម្មវិធី គណៈអធិបតីទាំងអស់ បានទស្សនកិច្ចនៅមណ្ឌលសិប្បកម្ម នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលមានទីតាំងជិតវត្តអង្គមន្ត្រី និងសាលាបឋមសិក្សា ចំណេះទូទៅ និងសិល្បៈ ព្រះសហគមន៍កាតូលិកផងដែរ។ បន្ទាប់មកគណៈអធិបតី អញ្ជើញមកបរិវេណសាលមហាស្រព និងបានកាត់ខ្សែបូណ៌រួមគ្នា ដើម្បីដាក់សម្ពោធឲ្យប្រើប្រាស់សាលមហោស្រពសិល្បៈនៅភូមិចំការទៀងជាផ្លូវការ ដោយមានរបាំនានាជាច្រើនប្រភេទ និងមកពីភូមិភាគទាំងបីនៃព្រះសហគមន៍កាតូលិក មកសម្ដែងអបអរសាទរ។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ បានមានប្រសាសន៍ស្វាគមន៍ ដល់ភ្ញៀវកិត្តិយស ក៏ដូចជាប្រជាជនទាំងអស់ ដែលបានចូលរួមនៅក្នុងអំណរសប្បាយរបស់ព្រះសហគមន៍ចំការទៀង ដែលបានប្រារព្ធកម្មវិធីសម្ពោធមហោស្រពយ៉ាងឱឡារិកនេះថា ពិធីនេះបានចូលរួមជាមួយបងប្អូនទាំងអស់ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មី នៅក្នុងប្រទេសកម្ពុជា និងថ្ងៃនេះជាថ្ងៃពិសេសដែលបានឲ្យយើងរួបរួមគ្នាជាមហាគ្រួសារតែមួយ នៅក្នុងការកសាងសេចក្ដីសុខសាន្ដដើម្បីឲ្យកម្ពុជាបន្តរីកចម្រើននៅក្នុងការគោរពគ្នាទៅវិញទៅមក និងសេរីភាព រួមជាមួយជីវិតដ៏ថ្លៃថ្នូរដែលនាំឲ្យយល់ពីតម្លៃនៃជីវិត។

លោកអភិបាលក៏បានបង្ហាញពីគោលបំណងនៃការកសាងសាលមហោស្រពដ៏ធំអស្ចារ្យនេះថា មហោស្រពជាមូលដ្ឋានយ៉ាងសំខាន់មួយ យើងមិនមែនគិតតែអំពីការសាងសង់អាគារថ្មីទៀតនោះទេ ប៉ុន្តែគិតធ្វើយ៉ាងមិចឲ្យកន្លែងហ្នឹងនាំឲ្យប្រជាជនក្នុងភូមិទេសចរណ៍ជាតិ អន្តរជាតិ បានស្គាល់វប្បធម៌ ប្រពៃណី សិល្បៈរបស់ខ្មែរ។

លោកបន្តថា លោកសង្ឃឹមថាកន្លែងនេះបន្តិចម្ដងៗអាចឲ្យភ្ញៀវទេសចរណ៍ ពេលគេធ្វើដំណើរទៅកែប និងកំពតអាចឈប់បានមួយម៉ោង ឬពីរម៉ោង ដើម្បីស្គាល់សិល្បៈប្រពៃណី វប្បធម៌ដ៏អស្ចារ្យ ដែលសម្ដែងដោយសិស្សសាលាសន្តហ្វ្រង់ស្វ័រ។ ម្យ៉ាងទៀតនៅទីនេះលោកកំពុងកសាងសាលាបឋមសិក្សា ផ្នែករបាំ ដើម្បីឲ្យកូនក្មេងចាប់ផ្ដើមមានឯកទេស ពីក្មេងទៅដូច្នេះពេលក្រោយទីនេះអាចមានទាំងរបាំចំរុះ ល្ខោនយីកេសៀក និងពហុសិល្បៈ ដើម្បីឲ្យទេសចរណ៍អន្តរជាតិស្គាល់ប្រទេសកម្ពុជា ស្គាល់ការរស់នៅដ៏អស្ចារ្យ នៅស្រុកស្រែផង។

លោកអភិបាល អូលីវីយេ បញ្ជាក់ថា អាចនិយាយបានថា កន្លែងនេះក្លាយទៅជាតំបន់អេកូទេសចរណ៍ សិប្បកម្ម និងសិល្បៈ។ សិប្បកម្ម គឺមានភូមិសិប្បកម្មត្បាញសូត្រ កាត់ដេរ រោងសិប្បកម្មកែច្នៃអាហារ កែច្នៃដូងយកប្រេង សាប៊ូ និងស្ករគ្រាប់ដូងជាដើម។ ខិតខំធ្វើយ៉ាងណាឲ្យស្រុកស្រែពោរពេញដោយជីវិតប្រសើរ និងនាំឲ្យប្រជាជនមានមោទនភាព ដោយបង្ហាញសិល្បៈ វប្បធម៌ប្រពៃណីរបស់គេ បង្ហាញស្នាដៃរបស់គេបាន។ នាំឲ្យស្រុកស្រែទីនេះ បន្តរីកចម្រើន និងនាំឲ្យប្រជាជនមានជីវិតរស់នៅល្អ ពោរពេញដោយសេចក្ដីសុខ សុភមង្គល និងនាំឲ្យប្រទេសកម្ពុជាទៅជាប្រទេសដ៏ល្បី តាមរយៈសិល្បៈ តាមរយៈវប្បធម៌។ លោកថា ពិតមែនស្នាដៃសិល្បៈនៃប្រទេសកម្ពុជា ទៅជាទ្រព្យសម្បត្តិនៃពិភពលោក។

បើតាមរយៈរបាយការណ៍របស់លោក អ៊ុំ សាមាន អ្នកទទួលខុសត្រូវកម្មវិធីសិល្បៈ បានបង្ហាញអំពីប្រវត្តិ និងបុព្វហេតុនៅក្នុងការកសាងសាលមហោស្រពសិល្បៈនេះ។ លោក សាមានបានឲ្យដឹងថា សាលមហោស្រពសិល្បៈនេះ បានផ្ដួចផ្ដើមឡើងដោយលោកអភិបាលអូលីវីយេ ក្នុងឆ្នាំ ២០១៧ ដើម្បីដឹកកកាយនូវវប្បធម៌របស់ខ្មែរឲ្យមានជីវិតរស់រវើកឡើងវិញ។ ក្រោយសាងសង់រួចសាលមហោស្រពនេះហើយ ក៏បានរៀបចំការសម្ដែងសិល្បៈចំរុះ ល្ខោនស្បែក ល្ខោនបាសាក់ និងយីកេ និងរបាំបូរាណ ប្រជាប្រិយ៍ផ្សេងផងដែរ ដែលសម្ដែងដោយ យុវសិស្សនៃសាលាសន្តហ្វ្រង់ស្វ័រ និងក្រុមសិល្បៈមកពីភ្នំពេញ។

លោក អ៊ុក សុជាតិ រដ្ឋលេខាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានកោតសរសើរដល់លោកអភិបាលអូលីវីយេ ដែលបានតស៊ូទាំងកម្លាំងស្មារតី កម្លាំងកាយ កម្លាំងចិត្ត និងសម្ភារ ដើម្បីរក្សាសម្បត្តិវប្បធម៌ រូបិយ និងអរូបិយរបស់ខ្មែរឲ្យមានជីវិតរស់ឡើងវិញ ដោយរក្សាអត្តសញ្ញាណដួងព្រលឹងរបស់ប្រទេសឲ្យគង់វង្សទុកជាមរតកសម្រាប់កូនចៅជំនាន់ក្រោយ។

លោកបន្ថែមទៀតថា ថ្ងៃនេះមិនគ្រាន់តែបង្កឲ្យប្រជាជនមានអំណរសប្បាយប៉ុណ្ណោះទេ ប៉ុន្តែបានផ្ទេរនូវចំណេះដឹងទំនៀមទម្លាប់ប្រពៃណីឲ្យគេដឹង គេស្គាល់ និងចូលរួមយ៉ាងសកម្មក្នុងការចងក្រងវប្បធម៌ខ្មែរគ្រប់ប្រភេទគ្រប់ទម្រង់ ដែលមាននៅមូលដ្ឋានរបស់យើង និងជំរុញឲ្យកម្ពុជាផ្សព្វផ្សាយវប្បធម៌ឲ្យបានទូលំទូលាយ។

លោក អ៊ុក សុជាតិ បន្តថា មហោស្រពចំការទៀងជាកន្លែងមួយ ដែលមហាជនកំពុងពេញនិយម និងមានជំនឿយ៉ាងជ្រាលជ្រៅ ហើយជាចលករមួយដែលចូលរួមចំណែកក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិឲ្យកាន់តែស្រឡាញ់ប្រទេសកម្ពុជាផងដែរ។

លោកអភិបាល អូលីវីយេ បានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការអភិវឌ្ឍតំបន់នេះតាំងពីឆ្នាំ២០០២មកម្ល៉េះ ពេលនោះលោកជាបូជាចារ្យទទួលខុសត្រូវនៅក្នុងតំបន់នេះ។ លោកបានកសាងសាលាមត្តេយ្យ ជាមត្តេយ្យម៉ុងតេស្សូរីតែមួយគត់នៅជនបទក្នុងប្រទេសកម្ពុជា បឋមសិក្សាចំណេះទូទៅ និងសិល្បៈ អនុវិទ្យាល័យ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងវិទ្យាស្ថានអប់រំកំរិតឧត្តមសិក្សាកាតូលិកតែមួយគត់ផងដែរ។ បង្កើតឲ្យមានមណ្ឌលសិប្បកម្ម សម្រាប់អភិវឌ្ឍន៍សហគមន៍ និងមណ្ឌលជនពិការ ភូមិសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ជាដើម។ល។ ចំពោះការលើកស្ទួយវិស័យសិល្បៈ វប្បធម៌ខ្មែរ គឺកំរិតកំពូលតែម្ដង។

# និស្សិតនៃវិទ្យាស្ថានសន្តប៉ូលបានទទួលជ័យលាភីលេខមួយក្នុងកម្មវិធីពានរង្វាន់ត្នោតមាស

និស្សិតនៃវិទ្យាស្ថានសន្តប៉ូលនៅខេត្តតាកែវ បានដណ្ដើមយកជ័យលាភីលេខមួយក្នុងកម្មវិធី "ពានរង្វាន់ត្នោតមាស ឆ្នាំ២០១៨" ដែលរៀបចំដោយ មូលនិធិគីណាល់ កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៨ នៅទីស្នាក់ការរបស់មូលនិធិគីណាល់ដែលជាសហគ្រាសផលិតឱសថប៉េប៉េអឹម នារាជធានីភ្នំពេញ។ កម្មវិធីប្រកួត "ពានរង្វាន់ត្នោតមាស ឆ្នាំ២០១៨" បង្កើតឡើង ក្នុងគោលបំណងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ និងបង្កើនគំនិតច្នៃប្រឌិតសម្រាប់ចូលរួមគាំទ្រដល់ការអភិវឌ្ឍជនបទក្នុងព្រះរាជាណាចក្រកម្ពុជា។ នេះជាលើកទី១ហើយដែលមូលនិធិបានរៀបចំកម្មវិធីនេះ ក្រោមប្រធានបទ "ការបង្កើនតម្លៃចេក" និងមាននិស្សិតចំនួន ១៩ក្រុម មកពីសាលានានាចូលរួមប្រកួត។ នៅក្នុងនោះវិទ្យាស្ថានសន្តប៉ូលមាននិស្សិតចំនួន២ក្រុមចូលរួម ហើយមួយក្រុមទទួលបានជ័យលាភីលេខមួយ ដោយបានកែច្នៃសំបកចេក ស្នូងចេក និងដើមចេក។

លោក ម៉ក់ រាជ្យ ជានិស្សិតរៀនផ្នែកកសិកម្មនៃវិទ្យាស្ថានសន្តប៉ូល និងជាក្រុមដែលបានទទួលជ័យលាភីលេខមួយ បានប្រាប់ថា កសិករកម្ពុជាសព្វថ្ងៃភាគច្រើនអាចកែច្នៃត្រឹមតែផ្លែចេកប៉ុណ្ណោះ ដោយបោះបង់សំបកចេក ស្នូងចេក និងដើមចេក ដូច្នេះក្រុមរបស់គាត់ក៏នាំគ្នារិះគិតអំពីកាកសំណល់ទាំងនេះ។ រាជ្យបានប្រាប់ទៀតថា ក្នុងកម្មវិធីប្រកួតនេះគណៈគ្រប់គ្រងវិទ្យាស្ថានសន្តប៉ូលមានការជម្រុញ និងគាំទ្រ ដើម្បីឲ្យក្រុមរបស់គាត់ធ្វើការស្រាវជ្រាវ។ ម៉ក់ រាជ្យ "យើង យកសាច់ចេកទៅធ្វើជាស្ករគ្រាប់ សំបកមកធ្វើជាតែនិងចម្រោះទឹក ដើមចេកនិងស្នូងចេកយកមកធ្វើជាក្រដាស ដើម្បីធ្វើការវិចខ្ចប់ស្ករគ្រាប់"។ និស្សិតដដែលបានបន្តថា ជ័យលាភីថ្ងៃនេះ មិនមែនសម្រាប់តែក្រុមយើងទេ គឺសម្រាប់វិទ្យាស្ថានសន្តប៉ូល ព្រោះថាវិទ្យាស្ថានបានយកចិត្តទុកដាក់ ទៅលើក្នុងការសិក្សារបស់និស្សិតគ្រប់ៗរូប និងមានសម្ភារគ្រប់គ្រាន់ដើម្បីឲ្យនិស្សិតធ្វើការសិក្សា និងធ្វើការស្រាវជ្រាវ។

លោក ផុន សុផល នាយកនៃវិទ្យាស្ថានសន្តប៉ូលឲ្យដឹងថា តាមគម្រោងរបស់សាលាសម្រាប់និស្សិតដែលទទួលជ័យលាភីនឹងទទួលបានការគាំទ្របន្ថែមទៀតលើការស្រាវជ្រាវបន្ថែម ជាពិសេសលើការអភិវឌ្ឍជនបទដល់ជនក្រីក្រតាមមូលដ្ឋាន និងដើម្បីលើកកម្ពស់តម្លៃចេក នៅក្នុងប្រទេស។ លោកបានបន្តទៀតថា រាល់អត្ថបទស្រាវជ្រាវរបស់និស្សិតទាំងពីរក្រុម សាលានឹងដាក់បញ្ចូលក្នុងបណ្ណាល័យ និងផ្តល់ជូនដល់ម្ចាស់មូលនិធិទុកជាឯកសារ។ បន្ថែមលើសនេះ អ្វីដែលនិស្សិតទាំងពីរក្រុមបានធ្វើ គឺនឹងយកទៅអនុវត្តផ្ទាល់នៅក្នុងសិប្បកម្មស្ករគ្រាប់ របស់លោកអភិបាលព្រះសហគមន៍ កាតូលិកភូមិភាគភ្នំពេញ។

ឯកឧត្តម យុទ្ធ ភូថង រដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា កម្មវិធីត្នោតមាសឆ្នាំ២០១៨ មានសារសំខាន់ណាស់ ដើម្បីឲ្យនិស្សិតមានចំណេះដឹងចំណេះធ្វើ គឺធ្វើជាទំពាំងស្នងឫស្សី ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ជាពិសេសប្រធានបទនៃការស្រាវជ្រាវនេះ គឺយកវត្ថុធាតុដើមដែលប្រជាកសិករនៅក្នុងប្រទេសកម្ពុជាមានស្រាប់ទៅកែច្នៃជាផលិតផលសិប្បកម្ម ឬឧស្សាហកម្ម ដើម្បីនាំចេញទៅលក់នៅក្រៅប្រទេស។ ឯកឧត្តមរដ្ឋលេខាធិការក៏បានបន្ថែមទៀតថា បច្ចុប្បន្នវិស័យកសិកម្មនៅប្រទេសកម្ពុជាបានប្រឈមនឹងបញ្ហាជាច្រើន ដូចជាបញ្ហាបច្ចេកវិទ្យាថ្មី បញ្ហាការប្រែប្រួលអាកាសធាតុ បញ្ហាការស្វែងរកទីផ្សារ។

លោកឱសថបណ្ឌិត ហៃ លីអ៊ាង ប្រធានមូលនិធិគីណាល់ បានពន្យល់ថា កម្មវិធីពានរង្វាន់ត្នោតមាសឆ្នាំ២០១៨ នេះ ជាក្តីស្រមៃរបស់លោកក្នុងការចូលរួមលើកតម្កើងការកែច្នៃផលិតផលកសិកម្ម នៅប្រទេសកម្ពុជាយើង។ នេះជាលើកទីមួយ នៃកម្មវិធីពានរង្វាន់ត្នោតមាស ដែលមានគោលបំណងចង់ឲ្យនិស្សិតដែលកំពុងរៀនកសិកម្ម យកចំណេះដឹងទៅជួយប្រជាកសិករ ដើម្បីចាប់ដៃជាមួយពួកគាត់ដោយពួកគាត់ជាអ្នកដាំ និស្សិតជាអ្នកកែច្នៃ ឲ្យផលិតផលរបស់ខ្មែរយើងមានអត្តសញ្ញាណផង និងដើម្បីបង្ហាញពីភាពអស្ចារ្យនៃសមត្ថភាពកែច្នៃ។

ការប្រកួតប្រជែងនេះ មានគណៈមេប្រយោគដែលដឹកនាំដោយ លោកសាស្ត្រាចារ្យ តាន់ ប៊ុនស៊ុយ និងមានការចូលរួមពីមេប្រយោគឯករាជ្យមួយចំនួន ដូចជា លោកប្រាក់ សេរីវឌ្ឍន៍ មកពីអង្គការ CIRD លោកសុខ សារ៉ែង មកពីអង្គការ ECOCERT លោកហ្សង់ ម៉ារីប្រេង់ (Jean-Marie Brun) មកពីអង្គការ IRAM លោក ហ៊ឹម ពិសិដ្ឋ តំណាងខនហ្វីរេល សម្រាប់វគ្គផ្តាច់ព្រ័ត្រ និងកញ្ញា អេឡែន អូប្រី (Hélène Obry) តំណាង ក្រុមហ៊ុនខនហ្វីរេល សម្រាប់វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ។

នៅវគ្គដំបូងនៃកម្មវិធីនេះ មាននិស្សិតចំនួន ១៩ក្រុម ដែលបានចុះឈ្មោះចូលរួមប្រកួតប្រជែង ក្រោមប្រធានបទ "ការបង្កើនតម្លៃចេក"។ ហើយនៅវគ្គផ្តាច់ព្រ័ត្រនេះ នៅសល់និស្សិតតែ៦ក្រុម ដែលបានចូលរួមធ្វើការប្រកួតប្រជែង គឺមាននិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម (ចំការដូង) វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (តិចណូ) និងវិទ្យាស្ថានសន្តប៉ូល។ ប្រធានបទដែលនិស្សិតទាំង៦ក្រុម លើកយកមកធ្វើការប្រកួតប្រជែងរួមមាន៖ ការប្រៀបធៀបម្សៅប៊ុចទីន ដែលចម្រាញ់បានពីសំបកចេកសើម និងចេកស្ងួត។ ការធ្វើឲ្យប្រសើរឡើងនៃដំណើរការផលិតម្សៅចេក។ ការធ្វើឲ្យប្រសើរឡើងនូវរសជាតិស្ករគ្រាប់ចេក។ គ្រប់ផ្នែកនៃដើមចេក គឺសុទ្ធតែមានតម្លៃ។ ការអភិវឌ្ឍទៅលើរសជាតិ វិធីសាស្ត្រក្នុងការផលិត និងប្រភពទីផ្សារនៃផលិតផលចេកឆាប។ ការកែច្នៃទឹកក្បុងចេក។

ក្រោយពីការវាយតម្លៃរបស់គណៈមេប្រយោគ គឺជ័យលាភីលេខមួយ បានទៅលើនិស្សិតមកពីវិទ្យាស្ថាន សន្តប៉ូល ក្រោមប្រធានបទ "គ្រប់ផ្នែកនៃដើមចេកគឺសុទ្ធតែមានតម្លៃ" ដោយទទួលបានទឹកប្រាក់ចំនួន ៤,០០០,០០០រៀល។ ជ័យលាភីជ័យលាភីលេខពីរ បានទៅលើនិស្សិតមកពីវិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា ក្រោមប្រធានបទ "ការអភិវឌ្ឍទៅលើរសជាតិ វិធីសាស្ត្រក្នុងការផលិត និងប្រភពទីផ្សារនៃផលិតផលចេកឆាប" ដោយទទួលបានទឹកប្រាក់ចំនួន ២,០០០,០០០រៀល និងជ័យលាភីលេខបី បានទៅលើនិស្សិតមកពីវិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា ក្រោមប្រធានបទ "ការធ្វើឲ្យប្រសើរឡើងនៃដំណើរការផលិតម្សៅចេក" ដោយទទួលបានទឹកប្រាក់ចំនួន ១,០០០,០០០រៀល។

*ដោយ សុវណ្ណភូមិ*




ថតដោយ

## សម្តេចប៉ាបរំលឹកព្រះសហគមន៍អេស្ប៉ាញ រឿងយុទ្ធនាការផ្សាយពាណិជ្ជកម្ម

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានលើកទឹកចិត្តអ្នកចូលរួម នៅក្នុងកិច្ចប្រជុំនៃក្រុមសាសនាអេស្ប៉ាញឲ្យចៀសវាងនូវយុទ្ធនាការបោះឆ្នោត ឬការផ្សាយពាណិជ្ជកម្មនេះ បើយោងតាមវ៉ាទីកង់ញូវ។

សារនេះ ត្រូវបានចេញតាមរយៈវីដេអូសម្រាប់ព្រឹត្តិការណ៍មួយ នៅក្នុងទីក្រុងម៉ាឌ្រិត ដែលរៀបចំឡើងដោយ វិទ្យាស្ថានទេវវិទ្យាជាតិ សម្រាប់ជីវិតសាសនា។ ព្រឹត្តិការណ៍នេះ បានចាប់ផ្តើមកាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ហើយនឹង ដំណើរការរហូតដល់ ថ្ងៃទី០៨ ដោយផ្តោតទៅលើយុវជន និងជីវភាពសាសនា។

សម្តេចប៉ាបបានរំលឹកថា "ការត្រាស់របស់ព្រះជាម្ចាស់ គឺកុំធ្វើកិច្ចការតាមរយៈគំរូនៃការធ្វើទីផ្សារ"។

នេះគឺជាសាររបស់សម្តេចប៉ាប ដោយសារតែក្តីបារម្ភថា យុវជនកំពុងតែបាត់បង់នូវឫសគល់នៃសាសនា ប៉ុន្តែព្រះសហគមន៍ត្រូវតែជៀសវាងសកម្មភាពបែបនោះ។

សម្តេចប៉ាបបានថ្លែងថា យើងមិនអាចនឹងដាក់កំណត់ខ្លួនយើងនោះទេ ប៉ុន្តែគួរតែសោកស្តាយនូវអ្វី ដែលកើតមានពីពេលកន្លងមក។ ព្រះជាម្ចាស់តែងតែប្រាប់យើងឲ្យសម្លឹងទៅមុខជានិច្ច ដូច្នេះយើងត្រូវតែធ្វើ។

សម្តេចប៉ាបបានជំរុញឲ្យមានការយកចិត្តទុកដាក់លើការបង្កើតក្រុមសន្ទនាអន្តរជំនឿ ស្តាប់នូវហេតុផល ពីយុវជន និងមជ្ឈឹមវ័យ ហើយអធិដ្ឋាន ដោយព្យាយាមណែនាំ ពួកគេឲ្យឈ្វេងយល់ពីហឫទ័យរបស់ព្រះជាម្ចាស់៕

## សម្តេចប៉ាបជួបជាមួយនឹងស្ថាបនិកមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្តីពីការអភិវឌ្ឍអាមេរិកឡាទិន

បណ្តាញព័ត៌មាន ហ្សឺរ៉ែណេត បានរាយការណ៍ថា កាលពីថ្ងៃទី០៦ ខែមេសាកន្លងទៅនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានទទួលជួប លោកស្រី ហេនរីយ៉ាន ឌឺ ឆាប៉ូណែ ដែលជាស្ថាបនិកនៃមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្តីពីការអភិវឌ្ឍន៍អាមេរិកឡាទិន មកពីទីក្រុងប៉ារីស ។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងជំនួបនោះ សម្តេចប៉ាបបានបង្ហាញនូវការគាំទ្ររបស់សម្តេចប៉ាបចំពោះ សកម្មភាពរបស់ មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្តីពីការអភិវឌ្ឍន៍អាមេរិកឡាទិន ទាក់ទិននឹងសិទ្ធិមនុស្ស និងការការពារភពផែនដី។

សម្តេចប៉ាបបានអះអាងថា ការការពារសិទ្ធិមនុស្ស និងពិភពផែនដីនេះ គឺជារឿងអាទិភាព ហើយបានវាយតម្លៃដ៏ខ្ពស់ចំពោះកិច្ចការដែលមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្តីពីការអភិវឌ្ឍន៍អាមេរិកឡានទីនបានធ្វើ និងរួមចំណែក ។

នាឱកាសនោះសម្តេចប៉ាប ក៏បានបង្ហាញនូវក្តីសង្ឃឹមថា ពិភពលោកអាចនឹងលុបបំបាត់គ្រោះអត់ឃ្លាន លើកកំពស់ក្តីស្រលាញ់បាន ប្រសិនបើយើងទាំងអស់គ្នា យកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស និងការការពារភពផែនដីនេះ ហើយក៏បានប្រកាសថា សម្តេចប៉ាប នឹងអធិដ្ឋាន ដើម្បីកិច្ចការទាំងអស់នេះទទួលបានជោគជ័យដើម្បីមនុស្សជាតិ៕

## ការអធិដ្ឋានរបស់សម្តេចប៉ាបនៅខែមេសានេះ គឺផ្តោតសំខាន់ទៅលើបញ្ហាសេដ្ឋកិច្ច

បើតាមបណ្តាញព័ត៌មាន ហ្សឺរ៉ែណេត បានឲ្យដឹងថា រាល់ការអធិដ្ឋានរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលបានធ្វើនៅក្នុងខែមេសានេះ គឺសម្តេចប៉ាបផ្តោតខ្លាំងទៅលើបញ្ហាសេដ្ឋកិច្ច ។

ប្រភពដដែលបានរាយការណ៍បន្តទៀតថា សម្តេចប៉ាបកំពុងតែអធិដ្ឋានជាពិសេសទៅអ្នកទទួលខុសត្រូវបញ្ហាសេដ្ឋកិច្ចទាំងអស់ នៅលើពិភពលោក ដើម្បីឲ្យពួកគេរិះគិតយ៉ាងណាដោះស្រាយបញ្ហាសេដ្ឋកិច្ចឲ្យរលូន។

សម្តេចប៉ាបបានបញ្ជាក់ថា សេដ្ឋកិច្ចមិនអាចគិតតែពីការប្រឹងប្រែង ដើម្បីតែប្រាក់ចំណូល ឬប្រាក់ចំណេញតែមួយមុខនោះទេ ប៉ុន្តែដាច់ខាតត្រូវតែរិះគិត អំពីការកាត់បន្ថយ កម្លាំងការងារ ហើយក៏ត្រូវរិះគិតដែរអំពីថ្លៃដើមផលិត។

សម្តេចប៉ាបបានអំពាវនាវឲ្យអ្នកដែលពាក់ព័ន្ធនឹងការងារសេដ្ឋកិច្ចរួម ទាំងមេដឹកនាំពាណិជ្ជករ អ្នកនយោបាយ អ្នករៀបចំគោលនយោបាយផ្សេងៗ គឺត្រូវតែគិតបញ្ហាមនុស្សជាតិ ជាចំណុចអាទិភាពមុនគេ ហើយក៏ត្រូវតែធ្វើរាល់អ្វីៗទាំងអស់ ដើម្បីលទ្ធភាពឈានទៅសម្រេចបាននូវឱកាសបង្កើនការងារ ប្រកបដោយសមធម៌។

សូមចូលរួមទាំងអស់គ្នា ដើម្បីឲ្យអ្នកសេដ្ឋកិច្ច បញ្ឈប់នូវការរិះគិតទាំងឡាយណា ដែលទាក់ទងនឹងសេដ្ឋកិច្ច ដែលគិតតែផលចំណេញ ប៉ុន្តែបំភ្លេចទំនួលខុសត្រូវសង្គម៕

## សម្តេចប៉ាបតែងតាំងអភិបាលឧបត្ថម្ភថ្មីប្រចាំនៅព្រះសហគមន៍ ឡូស អង់ ជីឡេស

បណ្តាញព័ត៌មានហ្សឺរ៉ែណេត បានរាយការណ៍កាលពីសប្តាហ៍មុនថា លោកម៉ាក ទ្រូឌូ ត្រូវបានសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ តែងតាំងជាអភិបាលឧបត្ថម្ភ សម្រាប់ព្រះសហគមន៍នៅទីក្រុង ឡូសអង់ជីឡេស។

លោក ម៉ាក ទ្រូឌូ ត្រូវបានគេដឹងថា គឺជានាយកសាលាទេវវិទ្យាល័យសន្ត យ៉ូហាន នៅក្នុងខាម៉ារីឡូ។

លោក ម៉ាក ទ្រូឌូ ត្រូវបានគេដឹងថា បានកើតនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥៧ នៅទីក្រុងហូលីវូត រដ្ឋកាលីហ្វ៉ញ៉ា នៃព្រះសហគមន៍ឡូសអង់ជីឡេស។

លោក គឺជាកូនភ្លោះ មួយរូប ហើយ គឺជាអតីត ទជ្ជបណ្ឌិត ក្រោយពេលដែលលោកបានធ្លាប់ឆ្លងកាត់ការងារជាច្រើនរាប់ចាប់តាំងពីក្មេង អ្នករត់សំបុត្រឡើងទៅ។ លោកត្រូវបានគេដឹងថា គឺជាអតីតអ្នកដែលរស់រានមានជីវិត ពីជំងឺមហារីកមួយប្រភេទ។

លោក ម៉ាក ទ្រូឌូ ត្រូវបានគេដឹងថា នឹងចូលរួមទទួលខុសត្រូវការងារ នៅក្នុងព្រះសហគមន៍នេះ ជាមួយនឹងអភិបាលឧបត្ថម្ភ ៥ នាក់ផ្សេងទៀត ដើម្បីជួយកិច្ចការការងាររបស់លោកអគ្គអភិបាល ចូសេ ហ្គោមេ។

លោកបានក្លាយជាបូជាចារ្យ កាលពីឆ្នាំ១៩៩១ ហើយក្លាយជានាយកសាលាទេវវិទ្យាល័យ កាលពីឆ្នាំ២០១៤ ៕

## សម្តេចប៉ាបអធិដ្ឋានជូនទារកម្នាក់ និងឪពុកម្តាយរបស់រូបគេ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចេញនូវសារមួយ ដោយបញ្ជាក់អំពីការយកចិត្តទុកដាក់របស់សម្តេចផ្ទាល់ទៅនឹងជីវិតរបស់ទារកមួយរូប ដែលកំពុងតែត្រូវបានសង្គ្រោះនៅមន្ទីរពេទ្យអង់គ្លេសមួយ។

បើតាមបណ្តាញព័ត៌មាន ហ្សឺរ៉ែណេត ទារកម្នាក់នេះ កំពុងតែស្ថិតនៅក្នុងលក្ខខណ្ឌ សង្គ្រោះដ៏ធ្ងន់ធ្ងរនៅក្នុងមន្ទីរពេទ្យមួយ នៅក្នុងទីក្រុង លីវើភូល នៃចក្រភពអង់គ្លេស ក្រោយពេលដែលរូបគេបានឆ្លងនឹងជំងឺដ៏កម្រមួយ ដែលធ្វើឲ្យសរសៃប្រសាទរបស់រូបគេ មិនលូតលាស់ ហើយមន្ទីរពេទ្យចង់បោះបង់ការខិតខំសង្គ្រោះជីវិតរូបគេ ដោយសារតែនោះ គឺជាស្ថានភាពជំងឺ ដែលពិបាកនៅក្នុងការព្យាបាល ហើយសុខភាពរបស់កុមាររូបនោះ ក៏មិនអំណោយផលថែមទៀត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ឪពុកម្តាយរបស់ទារកម្នាក់នេះមិនព្រម ហើយកំពុងតែឈានដល់ការប្តឹងផ្តល់ដល់តុលាការថែមទៀត។

ទារកម្នាក់នេះត្រូវបានគេដឹងថា ឈ្មោះ អាល់ហ្វី អេវ៉ាន ហើយសម្តេចប៉ាប បានប្រកាសថា សម្តេចបានកំពុងតែអធិដ្ឋានដល់រូបគេ និងឪពុកម្តាយរបស់ពួកគេ ដើម្បីឲ្យគ្រូពេទ្យបន្តព្យាបាល និងឲ្យរូបគេអាចជួយសង្គ្រោះបាន។

គួររំលឹកថា អាលហ្វី អេវ៉ាន មិនមែនទើបតែចូលសម្រាកនៅមន្ទីរពេទ្យនោះទេ គឺរូបគេបានចូលមន្ទីរពេទ្យតាំងតែពី ឆ្នាំ ២០១៦ មកឯណោះ ក្រោយពេលដែលរូបគេបានឆ្លងមេរោគ ទាក់ទងនឹងប្រព័ន្ធដកដង្ហើម និងសួត ប៉ុន្តែស្ថានភាពជំងឺរបស់គេ ចេះតែបន្តធ្ងន់ទៅៗក្រោយការព្យាបាល ដូច្នេះហើយបានជាមន្ទីរពេទ្យចង់បញ្ឈប់ការព្យាបាល ប៉ុន្តែឪពុកម្តាយរបស់គេបានបដិសេធ។

លោកស្រី ខេត ជេម និងលោក ថុម អេវ៉ាន ដែលជាឪពុកម្តាយរបស់ អាលហ្វី អេវ៉ាន បានប្រឆាំងនឹងគោលបំណងរបស់ពេទ្យ ដោយអះអាងថា ទារករូបនេះ កំពុងតែមានស្ថានភាពប្រសើរ ហើយកំពុងតែតស៊ូតាមផ្លូវច្បាប់ ដើម្បីបន្តឲ្យគ្រូពេទ្យបន្តការសង្គ្រោះជីវិតរូបគេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មន្ទីរពេទ្យ បានអះអាងថា គ្រូពេទ្យចង់បញ្ឈប់ការព្យាបាល៕

# វិទ្យាស្ថានសន្តប៉ូល (SPI) បង្កើតឱកាសស្វែងរកការងារឲ្យនិស្សិត



វិទ្យាស្ថានសន្តប៉ូល(SPI) បានរៀបចំ ជំនួបរវាងតំណាងនិស្សិតវិទ្យាស្ថានសន្តប៉ូល ជាមួយបណ្តាក្រុមហ៊ុន សហគ្រាស ក៏ដូចជា ស្ថានទូតចំនួន២៤ស្ថាប័ន នារាត្រីថ្ងៃទី២៦ មីនា ២០១៨ នៅលើទូកទេសចរណ៍តាម ដងទន្លេចតុមុខ ដើម្បីផ្សព្វផ្សាយអំពីវិទ្យាស្ថានសន្តប៉ូល។ ជាពិសេសដើម្បីផ្តល់ ឱកាសដល់និស្សិតក្នុងការស្វែងរកការងារ ក្រោយបញ្ចប់ការសិក្សា។

បន្ទាប់ពីកិច្ចស្វាគមន៍របស់លោកអភិបាលអូលីវីយេ ដ្មឹតអីស្លែរ ដែលជាស្ថាបនិក របស់វិទ្យាស្ថានសន្តប៉ូល ចំពោះភ្ញៀវកិត្តិយសទាំង២៤ស្ថាប័នរួចមក លោក ផុន សុផល នាយកវិទ្យាស្ថានសន្តប៉ូល បានធ្វើ បទបង្ហាញអំពីវិទ្យាស្ថានសន្តប៉ូល។ វិទ្យាស្ថានសន្តប៉ូល មានប្រាំមហាវិទ្យាល័យ សម្រាប់ថ្នាក់បរិញ្ញាបត្រ និងប្រាំពីរជំនាញ ទៀតសម្រាប់ថ្នាក់បរិញ្ញាបត្ររង ព្រមទាំង មានអន្តេវាសិកដ្ឋានសម្រាប់និស្សិតដែល មកពីខេត្តឆ្ងាយ។ ក្រៅពីការផ្តល់នូវការ អប់រំចំណេះដឹង និងជំនាញ លោកផុន សុផល បានបង្ហាញអំពីកម្មវិធី និងសកម្មភាពដទៃទៀតដែលវិទ្យាស្ថាបានលើកទឹក ចិត្ត និងជំរុញឲ្យនិស្សិតចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសង្គម និងបរិស្ថាន។

ក្រោយពេលបញ្ចប់បទបង្ហាញ កម្មវិធី នេះក៏បានផ្តល់ឱកាសឲ្យនិស្សិត ជួបជា មួយតំណាងស្ថាប័នទាំងនោះ ដើម្បីឈ្វេង យល់បន្ថែមនូវគុណសម្បត្តិរបស់និស្សិត វិទ្យាស្ថានសន្តប៉ូល ក៏ដូចជាជួយឲ្យនិស្សិត ស្គាល់ និងឈ្វេងយល់អំពីចំណុចពិសេសៗ ដែលជាតម្រូវការរបស់ស្ថាប័នទាំងនោះ។

តាមប្រសាសន៍របស់លោកអភិបាល អូលីវីយេ បានឲ្យដឹងថា តាមពិតវិទ្យាស្ថាន បានគិតដល់ការអភិវឌ្ឍប្រទេសកម្ពុជាទាំង មូល ព្រមទាំងជួយនិស្សិតមួយចំនួនបញ្ចប់ ការសិក្សាផ្នែកកសិកម្ម និងទេសចរណ៍ អាច ធ្វើការនៅតាមជនបទ តាមខេត្ត ដើម្បី អភិវឌ្ឍប្រទេសកម្ពុជា ដោយមិនសំដៅ លើតែទីក្រុងភ្នំពេញនោះទេ។

ជាមួយគ្នានេះដែរ លោកផុន សុផល បានឲ្យដឹងអំពីជំនួបរវាងនិស្សិត និងក្រុមហ៊ុននានាពេលនេះ គឺដើម្បីឲ្យស្ថាប័នទាំង នោះមានកិច្ចសហប្រតិបត្តិការណ៍ជាមួយ វិទ្យាស្ថាន ក្នុងការទទួលនិស្សិតឲ្យធ្វើការ ក្រោយបញ្ចប់ឆ្នាំទីបួន ហើយក៏ជាឱកាស សម្រាប់និស្សិតដើម្បីភ្ជាប់ទំនាក់ទំនងជា មួយក្រុមហ៊ុននានា មុននឹងចុះកម្មសិក្សា នៅខែឧសភាខាងមុខ។

លោកនាយកវិទ្យាស្ថានក៏សង្ឃឹមផង ដែរថា ក្រោយពីជំនួបនេះរួចក្រុមហ៊ុន ទាំងអស់នឹងស្គាល់វិទ្យាស្ថានកាន់តែច្បាស់ ពីការអប់រំរបស់វិទ្យស្ថាន និងសង្ឃឹមថា និស្សិតអាចរកបានការងារនៅកន្លែងត្រឹម ត្រូវតាមជំនាញ។

តាមប្រសាសន៍របស់លោក Philippe CHATIGNOUX ជាប្រធានរតនាគារនៃ ស្ថានទូតបារាំងបានឲ្យដឹងថា កម្មវិធីនេះ ពិតជាពិសេសព្រោះបានផ្តល់ឱកាសដល់ និស្សិតដែលមកពីជនបទមានទំនាក់ទំនង ជាមួយក្រុមហ៊ុនឯកជន។ លោកថាក្រុមហ៊ុនកំពុងត្រូវការបុគ្គលិកវ័យក្មេងដើម្បី អភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដើម្បីចូល ក្នុងទីផ្សារការងារ។ លោកក៏បានសំណូម ពរឲ្យមានការតាមដានព័ត៌មានជាមួយនឹង ស្ថាប័នទាំងនេះជាបន្តបន្ទាប់ ក្រោយពី ជំនួបនេះ ដើម្បីជាប្រយោជន៍ដល់និស្សិត ក្នុងការស្វែងរកការងារ។

រីឯលោក វេជ្ជបណ្ឌិត លី អ៊ុំហៃ ជា ប្រធានរោងចក្រផលិតឱសថ PPM បាន មានប្រសាសន៍ថា SPI មានគុណសម្បត្តិ ធំក្នុងការបង្កើតកន្លែងអប់រំនៅជនបទ ហើយនៅជនបទគឺជាកន្លែងដែលយើង ចាំបាច់ត្រូវធ្វើការអភិវឌ្ឍ ជាពិសេសសម្រាប់ និស្សិតដើម្បីអភិវឌ្ឍន៍នៅស្រុកកំណើត របស់ខ្លួន។ លោកបន្តថា កម្មវិធីនេះល្អ ខ្លាំងណាស់ដែលបានជួបជាមួយកូនសិស្ស ផ្ទាល់ ព្រមទាំងបានដឹងអំពីការអប់រំ និង កម្មវិធីផ្សេងៗទៀតរបស់វិទ្យាស្ថាន ដែល ជាឱកាសដ៏ល្អមួយដើម្បីដឹងពីការចង់បាន របស់និស្សិត និងការចង់បានរបស់ក្រុមហ៊ុន។ លោកថា លោកចាប់អារម្មណ៍ខ្លាំង ចំពោះនិស្សិត SPI ព្រោះថាគោលដៅ របស់លោក គឺបង្កើតរោងចក្រនៅជនបទ រីឯបុគ្គលិកដែលលោកត្រូវការ គឺត្រូវ ស្រឡាញ់ទឹកដីដែលជាកន្លែងរស់នៅរបស់ គាត់ និងត្រូវយល់ថាមាសប្រាក់របស់គាត់ មិនមែននៅទីក្រុង តែនៅលើទឹកដីរបស់ គាត់ដែលត្រូវការកែច្នៃដូចអ្វីដែលវិទ្យាស្ថាន បានធ្វើនៅតាកែវ និងភ្នំវល្លិ៍។

និស្សិតដែលមកចូលរួមនៅថ្ងៃនេះមាន និស្សិតផ្នែកកសិកម្ម ភាសាអង់គ្លេស គ្រប់គ្រងទេសចរណ៍ សង្គមកិច្ច និងព័ត៌មានវិទ្យា។

វិទ្យាស្ថានសន្តប៉ូល ជាគ្រឹះស្ថានឧត្តម សិក្សាកាតូលិកតែមួយគត់នៅកម្ពុជាបាន បង្កើតឡើងក្នុងឆ្នាំ២០០៩ ដោយលោក អភិបាលអូលីវីយេ ដ្មឹតអីស្លែរ ដើម្បីជួយ ដល់យុវជនក្រីក្រ និងយុវជននៅតាមជន បទអាចបន្តការសិក្សា ដោយមិនចាំបាច់ មករាជធានីភ្នំពេញ។

ឆ្លងតាមរយៈបទពិសោធន៍កន្លងមក ជារៀងរាល់ឆ្នាំនិស្សិតដែលបានបញ្ចប់ ការសិក្សានៅវិទ្យាស្ថានសន្តប៉ូលតែងតែ ទទួលបានការងារធ្វើនៅតាមអង្គការ ក្រុមហ៊ុនឯកជននានា តាមរយៈទំនាក់ទំនង រវាង SPI និងស្ថាប័ននានាជាច្រើនលើក ច្រើនសារតាមរូបភាពផ្សេងៗ។ នេះជា លើកទីពីរ ដែល SPI បានរៀបចំឲ្យមាន ទំនាក់ទំនងនិងការផ្សព្វផ្សាយតាមទ្រង់ ទ្រាយបែបនេះ។ ក្រៅពីជួយស្វែងរកការ ងារឲ្យនិស្សិត វិទ្យាស្ថានសន្តប៉ូល ក៏មានកិច្ចសហប្រតិបត្តិការណ៍ជាមួយសាកលវិទ្យាល័យនានានៅក្រៅប្រទេស ដោយមាន អនុស្សារណៈយោគយល់ និងបានបញ្ជូន និស្សិតឲ្យបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅ ប្រទេសកូរ៉េ ថៃ ភីលីពីន និងសិង្ហបុរីជា ដើម។ល។

*ដោយ ដាលីស*

# លិខិតអបអរសាទរ




**អបអរសាទរ និងកោតសរសើរចំពោះ**
**និស្សិតនិស្សិតផ្នែកកសិកម្ម នៃវិទ្យាស្ថានសន្តប៉ូល**
**ទាំងបីរូប ដែលបានទទួលជ័យលាភី**

**លេខ**

# ១

ក្នុងឱកាសនៃការប្រកួតប្រជែងអត្ថបទស្រាវជ្រាវលើវិស័យកសិកម្ម និងចំណីអាហារ ដើម្បីឈានទៅដណ្តើម "**ពានរង្វាន់ត្នោតមាសឆ្នាំ ២០១៨**" ដែលប្រារព្ធឡើងកាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៨ កន្លងទៅនេះ ក្រោមប្រធានបទ "**គ្រប់ផ្នែកនៃដើមចេកគឺសុទ្ធតែមានតម្លៃ**"

នៅក្នុងនាមជាគណៈគ្រប់គ្រង សាស្ត្រាចារ្យ បុគ្គលិកគ្រប់ផ្នែក ព្រមទាំងនិស្សិតទាំងអស់ នៃវិទ្យាស្ថានសន្តប៉ូល មានមោទនភាពយ៉ាងក្រៃលែងចំពោះលទ្ធផលនេះ
សូមព្រះជាម្ចាស់ប្រទានពរ ។

http://spi.edu.kh/


Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវេរីតាស់អាស៊ីខេមរភាសា

សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| **ភ្នំពេញ** | : FM 103 Mhz | **ម៉ោង ៨:00- ៩:00 យប់** |
| **បាត់ដំបង** | : FM 91 Mhz | **ម៉ោង ៧:00- ៨:00 យប់** |
| **ក្រុងសៀមរាប** | : FM 100.5 Mhz | **ម៉ោង ៥:00- ៦:00 រសៀល** |
| **ក្រុងស្ទឹងសែន ខេត្តកំពង់ធំ** | : FM 103.5 Mhz | **ម៉ោង ៧:00- ៨:00 យប់** |
| **ក្រុងកំពង់ចាម** | : FM 100.5 Mhz | **ម៉ោង ៧:00- ៨:00 យប់** |
| **ព្រះសីហនុ** | : FM 100.5 Mhz | **ម៉ោង ៦:00- ៧:00 យប់** |
| **ក្រុងកំពត** | : FM 93.25 Mhz | **ម៉ោង ៥:00- ៦:00 រសៀល** |

- លោកអ្នកក៏អាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com, www.catholiccambodia.org

- លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

**✤ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com